USAID
FROM THE AMERICAN PEOPLE

# សៀវភៅ

# បច្ចេកទេស

# ចិញ្ចឹមត្រី





សម្រាប់អាជីវកម្មចិញ្ចឹមត្រីខ្នាតតូច និងខ្នាតមធ្យមនៅកម្ពុជា

ខែ សីហា ឆ្នាំ២០០៨

សៀវភៅនេះបោះពុម្ពដោយ **គម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមនៅកម្ពុជា** ដែលឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិសំរាប់ប្រជាជនកម្ពុជា ដើម្បីពង្រឹងអាជីវកម្មចិញ្ចឹមត្រី របស់ពួកគេ។

**រៀបចំដោយ** : លោក **ព្រំ គឹមហ** លោកស្រី **ទ្រី រតនា** លោកស្រី Merrilene Peramune និងក្រុមការងារ **គម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមនៅកម្ពុជា** អង្គការ **ឌី អេ អាយ** (DAI)។

**កែសម្រួលដោយ: ការិយាល័យវារីវប្បកម្ម** នៃរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

សៀវភៅនេះផ្តល់ដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ
តាមរយៈ
គម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និង ខ្នាតមធ្យមនៅកម្ពុជា
បន្ទប់លេខ ៥៨៨ អាគារ “F” ភ្នំពេញសិនធើរ
ទន្លេបាសាក់ រាជធានីភ្នំពេញ
គេហទំព័រ : www.cambodiamsme.org
អ៊ីមែល : cambodiamsme@dai.com
ទូរស័ព្ទ : ៨៥៥-២៣ ២២២ ៤៨៦
ទូរសារ : ៨៥៥-២៣ ២២២ ៤៨៥

**បញ្ជាក់:**

ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនបានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលអាមេរិកនោះទេ។

# អារម្ភកថា

## វិស័យវារីវប្បកម្មនៅប្រទេសកម្ពុជា

ទោះបីជាប្រទេសកម្ពុជាសំបូរទៅដោយទន្លេ ស្ទឹង បឹងបួរ ប្រកបដោយធនធានជលផលយ៉ាងច្រើនយ៉ាងណាក៏ដោយ ក៏ធនធានទាំងនោះកំពុងជួបប្រទះនូវការថយចុះយ៉ាងខ្លាំងដោយសារការនេសាទហួសកំរិត និងការបំផ្លាញប្រព័ន្ធអេកូឡូស៊ី។ ត្រីជាម្ហូបអាហារចំបងរបស់ប្រជាជនកម្ពុជា។ វិស័យវារីវប្បកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជាម្ហូបអាហារសម្រាប់ជីវភាពរស់នៅប្រកបដោយនិរន្តភាព និងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបរិស្ថាន។ បច្ចុប្បន្ននេះ វិស័យវារីវប្បកម្មមានការលូតលាស់យ៉ាងខ្លាំង ដែលជាឱកាសសម្រាប់គ្រួសារចិញ្ចឹមត្រី ដែលផលចិញ្ចឹមរបស់គាត់មានការផ្លាស់ប្តូរពីការចិញ្ចឹមសម្រាប់ជាអាហារប្រចាំគ្រួសារ ទៅជាការចិញ្ចឹមសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងមូលដ្ឋាន ក្នុងខេត្ត និងទីផ្សារទូទាំងព្រះរាជាណាចក្រកម្ពុជា។

## គម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមនៅកម្ពុជា

អង្គការ ឌី អេ អាយ (DAI) កំពុងអនុវត្តគម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និង ខ្នាតមធ្យមនៅកម្ពុជា ក្រោមជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ដើម្បីធ្វើការជាមួយបណ្តាអាជីវករឱ្យជំនះលើឧបសគ្គបច្ចេកទេសនានា និងកែលំអទំនាក់ទំនងអាជីវកម្ម ផលិតកម្ម សេវាកម្ម និងបរិយាកាសអាជីវកម្ម។ ផ្នែកវារីវប្បកម្ម គឺជាមុខរបរអាជីវកម្មមួយ

ក្នុងចំណោមអាជីវកម្មសំខាន់ៗ ដែលគម្រោងបានអនុវត្តជាមួយនៅក្នុងខេត្តកណ្តាល ព្រៃវែង កំពង់ចាម ស្វាយរៀង កំពង់ស្ពឺ និងខេត្តក្រចេះ ដើម្បីជួយឱ្យប្រសើរឡើងនូវបច្ចេកទេសចិញ្ចឹម បង្កើនគុណភាពផលិតផលចរាចរលើទីផ្សារ និងបង្កើតបណ្តាញទំនាក់ទំនងទីផ្សារក្នុងខ្សែសង្វាក់អាជីវកម្មចិញ្ចឹមត្រីក្នុងព្រះរាជាណាចក្រកម្ពុជា។

សៀវភៅបច្ចេកទេសចិញ្ចឹមត្រីនេះ នឹងបំពេញចន្លោះប្រហោងនៃការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារដើម្បីឱ្យក្លាយទៅជាមុខរបរអាជីវកម្មយ៉ាងពិតប្រាកដ។ ឯកសារនេះរួមបញ្ចូលគ្នានូវជំនាញបច្ចេកទេសដែលចាំបាច់ ជាមួយនឹងជំនាញផ្នែកអាជីវកម្មដែលពួកគេត្រូវការ ដូចជាការកត់ត្រាចំណូល-ចំណាយ និងផ្នែកទីផ្សារ។ វាបង្ហាញពីរបៀបក្នុងការចាប់ផ្តើមអាជីវកម្មពីខ្នាតតូច និងធ្វើការពង្រីកអាជីវកម្មនេះ តាមរយៈការបណ្តាក់ទុនបន្ថែមជាមួយនឹងប្រាក់ចំណេញ។ ឧទាហរណ៏មួយចំនួននៃគំរូអាជីវកម្មខ្នាតផ្សេងៗគ្នាដែលទទួលបានជោគជ័យ ត្រូវបានលើកឡើងដើម្បីជាការលើកទឹកចិត្តដល់សហគ្រិន និងដើម្បីបង្ហាញឱ្យឃើញថាអាជីវករគ្រប់ៗគ្នាអាចប្រកបរអាជីវកម្មផ្នែកវារីវប្បកម្មដោយជោគជ័យ ប្រសិនបើពួកគេយល់ដឹងពីជំនាញបច្ចេកទេស និងជំនាញអាជីវកម្មថ្មីៗ។



**លោក ឃឺតធីស ហាន់លី**

**ប្រធានគម្រោងអភិវឌ្ឍន៏សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច**
**និងខ្នាតមធ្យមនៅកម្ពុជា**

## មាតិការអត្ថបទ


**មុខរបរអាជីវកម្មចិញ្ចឹមត្រី** ........................................................ ០១

    ហេតុអ្វីបានជាការចិញ្ចឹមត្រីមានសារៈសំខាន់សម្រាប់លោកអ្នក និង សម្រាប់ប្រជាជនកម្ពុជា? ........................................................ ០១

    តើអ្វីដែលជាកត្តាចាំបាច់ក្នុងការចាប់ផ្តើមមុខរបរចិញ្ចឹមត្រី? ................ ០២

**បច្ចេកទេសចិញ្ចឹមត្រី** ........................................................ ០៣

    ការជ្រើសរើសទីតាំង និង របៀបនៃការជីកស្រះចិញ្ចឹមត្រី ..................... ០៣

    ការរៀបចំស្រះមុនពេលដាក់កូនត្រីចិញ្ចឹម ......................................... ០៦

    បច្ចេកទេសសំខាន់នៃការចិញ្ចឹមត្រីប្រភេទត្រីកាប និងត្រីទីឡាព្យា .......... ០៨

    ការជ្រើសរើសកូនត្រីពូជសម្រាប់ដាក់ចិញ្ចឹម ..................................... ១០

**ការដឹកជញ្ជូនកូនត្រីពូជ** ........................................................ ១៤

**ចំនួនកូនត្រីពូជដាក់ចិញ្ចឹម** ........................................................ ១៦

**ការប្រមូលផលត្រី** ........................................................ ២៩

    ការប្រមូលផលត្រីរំលោះ ........................................................ ២៩

    ការប្រមូលផលត្រីសរុប ........................................................ ២៩

**ទីផ្សារ និងផ្សារលក់ផលិតផល** ........................................................ ៣១

    ទីផ្សារក្នុងឃុំ ........................................................ ៣១

    ទីផ្សារក្នុងខេត្ត ........................................................ ៣១

    ទីផ្សារក្នុងខេត្តកណ្តាល ខេត្តសៀមរាប និងទីក្រុងភ្នំពេញ ...................... ៣១

**កត្តាប្រុងប្រយ័ត្នលើការងារចិញ្ចឹមត្រី** ........................................................ ៣៣

**ការចំណាយទុនដើម្បីបង្កើនលើមុខរបរចិញ្ចឹមត្រី** ..................................... ៣៦

    ករិតមុខរបរទី១ ........................................................ ៣៧

ក៏រិតមុខរបរទី ២ ............................................................................៣៧
ក៏រិតមុខរបរទី ៣ ............................................................................៣៨
**ករណីជោគជ័យលើមុខរបរចិញ្ចឹមត្រី**.......................................................៤០
ករណីទី ១.......................................................................................៤០
ករណីទី ២.......................................................................................៤២
ករណីទី ៣.......................................................................................៤៥
ករណីទី ៤ .......................................................................................៤៧
**ឧបសម្ព័ន្ធ ១:** គំរូកត់ត្រាការវិភាគចំណូល-ចំណាយ សំរាប់មុខរបរចិញ្ចឹមត្រី....៥០

## មុខរបរអាជីវកម្មចិញ្ចឹមត្រី

វារីវប្បកម្មផ្តល់ឱកាសដល់អាជីវករចិញ្ចឹមត្រីដើម្បីជាការចាប់ផ្តើម និងពង្រីកមុខរបរចិញ្ចឹមត្រីឱ្យមានភាពជាក់លាក់ដោយបង្កើនទុនបន្ថែម។ ក្នុងករណីការចិញ្ចឹមត្រីជាលក្ខណៈទ្រង់ទ្រាយតូច ដែលប្រើប្រាស់សម្រាប់អាហារូបត្ថម្ភប្រចាំគ្រួសារ អាចជាជំហានដំបូងក្នុងការប្រកបមុខរបរចិញ្ចឹមត្រី ព្រោះថា ជាការសំខាន់មិនថា ការចាប់ផ្តើមមុខរបររបស់អ្នកជាលក្ខណៈទ្រង់ទ្រាយតូច ឬធំនោះទេពោលគឺ ការចិញ្ចឹមតាមលក្ខណៈបច្ចេកទេសវាជាកត្តាសំខាន់ដែលអាចជួយអ្នកឱ្យចំណេញពេលវេលា និងធានាថាអាចទទួលបានផលចំណេញពីមុខរបររបស់ខ្លួន។ ការពង្រីកមុខរបរចិញ្ចឹមត្រីតាមលក្ខណៈបច្ចេកទេសគឺជាជំហានដំបូងយ៉ាងសំខាន់ ដើម្បីធ្វើយ៉ាងណាឱ្យការចិញ្ចឹមទទួលបានទិន្នផលខ្ពស់ និងចំណេញ។

## ហេតុអ្វីបានជាការចិញ្ចឹមត្រីមានសារៈសំខាន់សម្រាប់លោកអ្នក និងសម្រាប់ប្រជាជនកម្ពុជា?

- ជាប្រភពប្រូតេអ៊ីន និង ជាអាហារដ៏មានឱជារស
- ជាប្រភពប្រាក់ចំណូលបន្ថែម
- បង្កើនផលិតផលត្រី និងកាត់បន្ថយការប្រើប្រាស់ធនធានជលផលពីធម្មជាតិ
- ប្រើប្រាស់ដីទំនេរ
- ប្រើប្រាស់ជាម្ហូបអាហារបន្ទាន់សម្រាប់គ្រួសារ និង សម្រាប់ភ្ញៀវជាមួយកម្មវិធីផ្សេងៗ

## តើអ្វីដែលជាកត្តាចាំបាច់ក្នុងការចាប់ផ្តើមមុខរបរចិញ្ចឹមត្រី?

- ត្រូវមានបទពិសោធន៍ ឬចំណេះដឹងលើការងារចិញ្ចឹមត្រី
- មានបំណងរៀនសូត្រ និង ទទួលយកនូវបច្ចេកទេសចិញ្ចឹមត្រី
- មានកំលាំងពលកម្ម ឬពេលវេលាគ្រប់គ្រាន់ក្នុងការប្រកបមុខរបរចិញ្ចឹមត្រី
- អាចរកទិញកូនត្រីពូជសម្រាប់ចិញ្ចឹមបាន
- ចំណីត្រីអាចផលិត និងរកបានក្នុងតំបន់
- មានស្រះ និង ផ្ទៃដីសម្រាប់ជីកស្រះ

# បច្ចេកទេសចិញ្ចឹមត្រី

## ការជ្រើសរើសទីតាំង និង របៀបនៃការជីកស្រះចិញ្ចឹមត្រី

### លក្ខខណ្ឌសម្រាប់ជ្រើសរើសទីតាំងស្រះចិញ្ចឹមត្រី

- មានទីតាំងជិតលំនៅដ្ឋាន
- មិនលិចទឹកជំនន់នៅរដូវវស្សា
- ជិតប្រភពទឹក
- ជាប្រភេទដីដែលអាចដក់ទឹកបានយ៉ាងតិចរយៈពេល ០៦ ខែ
- មិនមានដើមឈើច្រើន
- មានទីតាំងជាប់ស្រែ ជាអំណោយផលយ៉ាងល្អសម្រាប់ការចិញ្ចឹមត្រីស្រែកា ដូចជា ត្រីឆ្ពិន ត្រីកាបស ត្រីកាបឥណ្ឌា និង ត្រីទីឡាព្យា។
- ទីតាំងស្រះចិញ្ចឹមត្រីគួរនៅឱ្យបានឆ្ងាយពីការប្រើប្រាស់សារធាតុពុលគ្រប់ប្រភេទ

### បច្ចេកទេសជីកស្រះ

- ស្រះចិញ្ចឹមត្រី ត្រូវជីកជារាងបួនជ្រុងទ្រវែង
- ស្រះគួរតែមានទំហំពី ១៥០-១៨០០ ម៉ែត្រការ៉េ និង មានជំរៅពី ១.៥-២.០ ម៉ែត្រ សម្រាប់ចិញ្ចឹមត្រីស្រែកា និង មានជំរៅពី ២.៥-៣.០ ម៉ែត្រ សម្រាប់ចិញ្ចឹមត្រីប្រា។ ជាមធ្យមស្រះចិញ្ចឹមត្រីមានទំហំ ៥០០ ម៉ែត្រការ៉េ ងាយស្រួលក្នុងការគ្រប់គ្រង។
- បាតស្រះត្រូវមានជំរាលទេរទៅជ្រុងម្ខាង




○ ស្រះត្រូវជីកឱ្យមានជំរាលសមស្រប ដើម្បីការពារការហូរច្រោះ។ ខាងក្រោមជាតារាងក៏រិតជើងទេរស្រះ អាស្រ័យប្រភេទដី និងរូបជាឧទាហរណ៍។

| ប្រភេទដី | ក៏រិតជើងទេរ |
|---|---|
| ល្បាយដីឥដ្ឋ | ១.០ ម៉ែត្រ |
| ល្បាយដីឥដ្ឋលាយខ្សាច់ ឬគ្រួស | ១.៥ ម៉ែត្រ |
| ល្បាយដីខ្សាច់លាយដីឥដ្ឋ | ១.៥-២.០ ម៉ែត្រ |



- ស្រះចិញ្ចឹមត្រីត្រូវមានទំនប់សម្រាប់ការពារការហូរចូលនូវកាកសំណល់មិនល្អ ឬសារធាតុពុលចូលក្នុងស្រះចិញ្ចឹមត្រី។
- ត្រូវដាំស្មៅលើទំនប់ស្រះ   ដើម្បីការពារការហូរច្រោះដែលបណ្តាលឱ្យទឹកស្រះល្អក់។
- ត្រូវបង្កប់ទុយោ   ឬសង់ប្រព័ន្ធតាមទំនប់ស្រះដើម្បីទុកសម្រាប់បង្ហូរទឹកចេញ-ចូល ( មើលរូបដូចខាងក្រោម)



**ប្រព័ន្ធបង្ហូរទឹកចូលស្រះ**



**ប្រព័ន្ធបង្ហូរទឹកចេញពីស្រះ**

# ការរៀបចំស្រះមុនពេលដាក់កូនត្រីចិញ្ចឹម

## ការរៀបចំស្រះចាស់

១- បូមទឹកឱ្យអស់ចេញពីស្រះ ដើម្បីចាប់ត្រីផ្ទក់ ឬត្រីរស់ ពស់ កង្កែប អន្ទង់ និងក្តាម ។

២- បូម ឬ បារភក់ចេញពីបាតស្រះឱ្យអស់ (សម្រាប់ការចិញ្ចឹមត្រីប្រា) និងបន្សល់ទុកភក់ជំរៅពី ០.១០ ទៅ ០.១៥ ម៉ែត្រ សម្រាប់ការចិញ្ចឹមត្រីស្រកា ។

៣- រៀបចំកែលំអស្រះ ដូចជា ជួសជុលទំនប់ស្រះ បិទរន្ធក្តាម និង រន្ធកង្កែប

## ការរៀបចំស្រះថ្មី

១- ការរៀបចំស្រះថ្មីមានដូចបង្ហាញក្នុងទំព័រទី ៣ (បច្ចេកទេសជីកស្រះ)

២- បូមទឹកបញ្ចូលស្រះប្រមាណពី ០.១-០.២ ម៉ែត្រ

## បន្ទាប់ពីការរៀបចំខាងលើ ទាំងស្រះចាស់ និងស្រះថ្មី យើងត្រូវៈ

១- បាចកំបោរប្រមាណពី ៥-១០ គក្រ ក្នុងផ្ទៃស្រះ ១០០ ម៉ែត្រការ៉េ ហើយទុកហាលថ្ងៃរយៈពេលពី ០២-០៣ ថ្ងៃ ដើម្បីកាត់បន្ថយជាតិពុល និងសំលាប់ពពួកបាក់តេរីក្នុងស្រះ ។

២- បញ្ចូលទឹកបន្ថែមក្នុងស្រះរហូតដល់កំរិតមួយដែលយើងចង់បាន រួចទុករយៈពេលពី ០២-០៣ ថ្ងៃ ដើម្បីបង្កើនចំណីធម្មជាតិនៅក្នុងស្រះចិញ្ចឹមត្រី (សម្រាប់ការចិញ្ចឹមត្រីស្រកា) ។

**សំគាល់:** កូនត្រីពូជអាចដាក់ចិញ្ចឹមក្នុងស្រះបានលុះត្រាតែទឹកស្រះមានពណ៌បៃតង (សម្រាប់ការចិញ្ចឹមត្រីស្រកា) ។

**អត្ថប្រយោជន៍នៃការប្រើកំបោរ**

១- កែលំអគុណភាពទឹក និង គុណភាពដី ដែលមានជាតិអាស៊ីត

២- សំលាប់ពពួកសត្វស៊ីកូនត្រីចិញ្ចឹម

៣- ជួយបង្កើនភាពថ្លានៃទឹកស្រះ

៤- ជួយបង្កើនការលូតលាស់ដល់ត្រី

**សំគាល់:** បរិមាណកំបោរដែលត្រូវប្រើ គឺអាស្រ័យទៅតាមប្រភេទនៃស្រះចាស់ ឬស្រះជីកថ្មីដែលត្រូវចិញ្ចឹមត្រី។

# បច្ចេកទេសសំខាន់នៃការចិញ្ចឹមប្រភេទត្រីកាប
# និង ត្រីទីឡាព្យា

បន្ទាប់ពីបាចកំបោរ និងទុកស្រះមួយរយៈ

១- បញ្ចូលទឹកក្នុងស្រះប្រមាណ 0.៥-១.0 ម៉ែត្រ

២- ប្រើជីសរីរាង្គ ឬប្រើជីគីមី

២.១- ប្រើជីសរីរាង្គ——ជីលាមកសត្វ

- ប្រសិនប្រើជីលាមកគោ ឬលាមកក្របី: ត្រូវដាក់ពី ៣0-៥0 គក្រ ក្នុងទំហំស្រះ ១00 ម៉ែត្រការ៉េ
- ប្រសិនប្រើជីលាមកសត្វជ្រូក: ត្រូវដាក់ពី ២0-៣៥ គក្រ ក្នុងទំហំស្រះ ១00ម៉ែត្រការ៉េ
- ប្រសិនប្រើជីលាមកសត្វមាន់: ត្រូវដាក់ពី ១0-១៥ គក្រ ក្នុងទំហំស្រះ ១00ម៉ែត្រការ៉េ
- ប្រសិនប្រើជីបៃតង: ត្រូវដាក់ពី ២0-៣0 គក្រ (ចងបាច់) ដាក់ត្រាំតាមជ្រុងនៃស្រះ។

២.២- ប្រើជីគីមី:

- ប្រើជី ដេ អា ប៉េ (DAP) ប្រមាណពី ៣00 ក្រាម ក្នុងទំហំស្រះ ១00 ម៉ែត្រការ៉េ
- និង ប្រើជីអ៊ុយរ៉េ (UREA) ប្រមាណពី ៧00 ក្រាម ក្នុងទំហំស្រះ ១00 ម៉ែត្រការ៉េ

បន្ទាប់មកទុករយៈពេលប្រមាណ ១សប្ដាហ៍ (០៧ ថ្ងៃ) ដើម្បីឱ្យកើតមានចំណី ធម្មជាតិក្នុងស្រះសម្រាប់ត្រី ដូចជា សត្វល្អិតតូចៗ (ហ្សូអូរប្លង់តុង) និង ប្លង់តុងរុក្ខជាតិ (ហ្វីតូប្លង់តុង) ។

**សំគាល់: ចំណីធម្មជាតិ គឺមានសារៈសំខាន់សម្រាប់កូនត្រីពូជនៅដំណាក់កាលដំបូង ព្រោះថាកូនត្រីពូជទាំងនោះពុំទាន់ស្គាល់ទីកន្លែងសម្រាប់ស៊ីចំណីបន្ថែមនៅឡើយ ។**

# ការជ្រើសរើសកូនត្រីពូជសម្រាប់ចិញ្ចឹម

ចំនុចសំខាន់ៗក្នុងការជ្រើសរើសកូនត្រីពូជសម្រាប់ចិញ្ចឹម ត្រូវផ្តោតទៅលើលក្ខខ័ណ្ឌចាំបាច់មួយចំនួនដូច ខាងក្រោម:

- ជាត្រីដែលមានការនិយមចូលចិត្តហូបពីប្រជាជនគ្រប់មជ្ឈដ្ឋាន ឬមានតំលៃនៅលើទីផ្សារ
- ជាប្រភេទកូនត្រីពូជដែលងាយស្រួលចិញ្ចឹមក្នុងទឹកស្រះ
- ជាប្រភេទកូនត្រីពូជដែលអាចរកទិញបាន
- ជាប្រភេទកូនត្រីពូជដែលធន់នឹងជម្ងឺ
- ជាប្រភេទត្រីដែលមានការអនុញ្ញាតពីរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ប្រភេទកូនត្រីពូជដែលគួរយកមកចិញ្ចឹមមានដូចជា ត្រីឆ្ពិន ត្រីគន្ធរ ត្រីព្រលូង ត្រីប្រា ត្រីទីឡាព្យា ត្រីកាបសាមញ្ញ ត្រីកាបស និងត្រីកាបឥណ្ឌា (ម្រិហ្គាល់) ព្រោះជាប្រភេទត្រីដែលបានធ្វើការសិក្សាស្រាវជ្រាវអំពីលក្ខណៈរស់នៅ និងការលូតលាស់ ហើយម្យ៉ាងទៀតជាប្រភេទត្រីដែលមានការអនុញ្ញាតពីរដ្ឋបាលជលផល ។

## តារាងទី ១: លក្ខណៈជីវសាស្ត្ររបស់ត្រី

| ប្រភេទត្រី | ចរិតរស់នៅ | ចរិតស៊ីចំណី | អត្រាលូតលាស់ ប្រចាំឆ្នាំ |
|---|---|---|---|
| **ត្រីឆ្ពិន**  | ជាប្រភេទត្រី ដែលចូលចិត្តរស់នៅស្រទាប់លើ និងស្រទាប់កណ្តាលនៃទឹក ។ | ជាប្រភេទត្រីដែលចូលចិត្ត: ○ស៊ីបន្លែ ចកបាយទា ត្រកួន និង កណ្តៀរ ○ស៊ីចំណីបន្ថែម | ២០០-៥០០ក្រាម |

| ប្រភេទត្រី | ចរិតរស់នៅ | ចរិតស៊ីចំណី | អត្រាលូតលាស់ប្រចាំឆ្នាំ |
|---|---|---|---|
| **ត្រីកន្ធរ**  | ជាប្រភេទត្រីដែលចូលចិត្តរស់នៅស្រទាប់លើ និងស្រទាប់កណ្ដាលនៃទឹក ។ | ជាប្រភេទត្រីដែលចូលចិត្តៈ<br>○ស៊ីបន្លែ ចកបាយទាត្រកួន និង កណ្ដៀវ<br>○ស៊ីចំណីបន្ថែម | ៥០-១០០ក្រាម |
| **ត្រីប្រា**  | ជាប្រភេទត្រីដែលចូលចិត្តរស់នៅស្រទាប់កណ្ដាល និងស្រទាប់បាតនៃទឹក ។ | ជាប្រភេទត្រីស៊ីចំណីចំរុះដែលមានជាតិសាច់ច្រើនៈ<br>○វាស៊ីពពួកកូនខ្យងក្ដាម ជន្លេន និងពពួកសត្វល្អិតផ្សេងៗ<br>○វាស៊ីចំណីបន្ថែម | ១-១.៥គក្រ |
| **ត្រីព្រលូង**  | ជាប្រភេទត្រីដែលចូលចិត្តរស់នៅស្រទាប់លើ និងស្រទាប់កណ្ដាលនៃទឹក ។ | ជាប្រភេទត្រីស៊ីចំណីចំរុះ ដែលមានជាតិសាច់ រុក្ខជាតិ និងគ្រាប់ធញ្ញជាតិៈ<br>○វាស៊ីពពួកកូនខ្យងក្ដាម ជន្លេន និងពពួកសត្វល្អិតផ្សេងៗ ។<br>○វាស៊ីចំណីបន្ថែម | ៣០០-៥០០ក្រាម |

| ប្រភេទត្រី | ចរិតរស់នៅ | ចរិតស៊ីចំណី | អត្រាលូតលាស់ប្រចាំឆ្នាំ |
|---|---|---|---|
| ត្រីទីឡាព្យា<br> | ជាប្រភេទត្រីដែលចូលចិត្តរស់នៅគ្រប់ស្រទាប់នៃទឹក។ | ជាប្រភេទត្រីស៊ីចំណីចំរុះ:<br>○ពពួករុក្ខជាតិក្នុងទឹក សារាយ<br>○វាស៊ីពពួកកូនខ្យងក្តាម ជន្លេន និង ពពួកសត្វល្អិតផ្សេងៗ<br>○វាស៊ីចំណីបន្ថែម | ៣០០-៥០០ក្រាម |
| ត្រីកាបស<br> | ជាប្រភេទត្រីដែលចូលចិត្តរស់នៅស្រទាប់លើ និង ស្រទាប់កណ្តាលនៃទឹក។ | ជាប្រភេទត្រីស៊ីប្លង់តុង ជាពិសេសរុក្ខជាតិប្លង់តុង | ៥០០-៧០០ក្រាម |
| ត្រីកាបឥណ្ឌា<br> | ជាប្រភេទត្រីដែលចូលចិត្តរស់នៅស្រទាប់លើ និង ស្រទាប់កណ្តាលនៃទឹក។ | ជាប្រភេទត្រីស៊ីចំណីចំរុះ:<br>○ពពួករុក្ខជាតិក្នុងទឹក សារាយ<br>○វាស៊ីពពួកកូនខ្យងក្តាម ជន្លេន និង ចកបាយទា<br>○វាស៊ីចំណីបន្ថែម | ៥០០-៧០០ក្រាម |

| **ប្រភេទត្រី** | **ចរិតរស់នៅ** | **ចរិតស៊ីចំណី** | **អត្រាលូតលាស់ ប្រចាំឆ្នាំ** |
|---|---|---|---|
| **ត្រីកាបសាមញ្ញ**  សំគាល់: ត្រីកាប សាមញ្ញ ចូលចិត្ត ឈូសជីជញ្ជាំងស្រះ និងបាតស្រះធ្វើឱ្យទឹកស្រះល្អក់។ ដូចនេះ ត្រីប្រភេទនេះ អនុញ្ញាតឱ្យដាក់ចិញ្ចឹមតែ ៥ ភាគរយ នៃចំនួនត្រីសរុបតែប៉ុណ្ណោះ។ | ជាប្រភេទត្រីរស់នៅស្រទាប់បាត | ជាប្រភេទត្រីស៊ីចំណីចំរុះ:<br>○ពពួករុក្ខជាតិក្នុងទឹក សារាយ<br>○វាស៊ីពពួកកូនខ្យងក្តាម ជន្លេន និងពពួកសត្វល្អិតផ្សេងៗ<br>○វាស៊ីចំណីបន្ថែម | ០.៥-១.០ គក្រ |

**អនុសាសន៍:** សម្រាប់ការចិញ្ចឹមតាមលក្ខណ:ទ្រង់ទ្រាយមធ្យម ការចិញ្ចឹមទោលវាជាការប្រសើរ ដូចជា ការចិញ្ចឹមត្រីប្រា ឬត្រីទីឡាព្យា ព្រោះវាងាយស្រួលក្នុងការតាមដាន និងថែរក្សាជាង។

## ការដឹកជញ្ជូនកូនត្រីពូជ

មានមធ្យោបាយជាច្រើនក្នុងការដឹកជញ្ជូនកូនត្រីពូជសម្រាប់យកទៅចិញ្ចឹម។ ទោះបីជាយ៉ាងណាក៏ដោយ មធ្យោបាយដែលសមស្របត្រូវបានជ្រើសរើស គឺអាស្រ័យទៅលើចំងាយផ្លូវ និងគុណភាពផ្លូវដែលត្រូវដឹកជញ្ជូន ហើយជាការល្អ ការដឹកជញ្ជូនកូនត្រីត្រូវធ្វើឡើងនៅពេលព្រឹក ឬពេលល្ងាច ជាពេលដែលមានអាកាសធាតុត្រជាក់។ កន្លងមករបៀបនៃការដឹកជញ្ជូនកូនត្រីពូជមានពីរបែប គឺការដឹកជញ្ជូនតាមលក្ខណៈបើកចំហ និង តាមលក្ខណៈបិតជិត។

- ការដឹកជញ្ជូនតាមលក្ខណៈបិតជិតៈ ជាទូទៅប្រើសម្រាប់ការដឹកជញ្ជូនផ្លូវឆ្ងាយ។ ការដឹកជញ្ជូនតាមបែបនេះត្រូវមានសំភារៈដូចជា ថង់ផ្លាស្ទិក កៅស៊ូកង បំពង់បញ្ចូលអុកស៊ីសែន និងកញ្ជេរសម្រាប់ដាក់ថង់កូនត្រី (បើសិនប្រើទោចក្រយាន ឬចក្រយានយន្ត)។

  ជាឧទាហរណ៍ៈ ប្រសិនបើថង់ផ្លាស្ទិកបណ្តោយ ១.០ ម៉ែត្រ និងទទឹង ០.៦ ម៉ែត្រ អាចដាក់កូនត្រីបានពី ៦០០-១០០០ កូនត្រី (បញ្ចូលទឹកមួយភាគបីនៃថង់) ប៉ុន្តែសម្រាប់ការដឹកជញ្ជូនផ្លូវឆ្ងាយ អាចដាក់បានពី ៣០០-៥០០កូនត្រី តែប៉ុណ្ណោះ។

- ការដឹកជញ្ជូនតាមលក្ខណៈបើកចំហៈ សម្រាប់ការដឹកជញ្ជូនផ្លូវជិត។ សំភារៈសម្រាប់ដឹកជញ្ជូនមាន កាធុនជ័រ ប៉ោត ឬកាដុងកាត់មាត់ចំហ។ ការដឹកជញ្ជូនបែបនេះមិនចាំបាច់ប្រើអុកស៊ីសែនជំនួយទេ។



ការបញ្ចូលអុកស៊ីសែនក្នុងថង់កូនត្រី



ការដឹកជញ្ជូនកូនត្រីដោយប្រើទោចក្រយានយន្ត

## ចំនួនកូនត្រីដាក់ចិញ្ចឹម

### ពេលវេលាសម្រាប់ដាក់កូនត្រីចិញ្ចឹមៈ

ជាទូទៅការចិញ្ចឹមត្រីអាចចាប់ផ្តើមពេលណាក៏បានដែរ ពោលគឺអាស្រ័យទៅលើប្រភពទឹកដែលមាន សម្រាប់ប្រើក្នុងការងារចិញ្ចឹមត្រីតែប៉ុណ្ណោះ ។

### ទំហំកូនត្រីពូជៈ

ទំហំកូនត្រីពូជអាចមានប្រវែងពី ៥-៦ សម (មើលក្នុងរូប) ព្រោះថាកូនត្រីពូជដែលមានទំហំប្រហាក់ប្រហែលនេះមានអត្រារស់បានល្អ និងមានលទ្ធភាពអាចគេចពីត្រីកាចបាន ។ ម្យ៉ាងទៀត កូនត្រីពូជត្រូវមានសុខភាពល្អ និងមានភាពរហ័សរហួន ។



ការចាប់កូនត្រីពីស្បៃមុងដោយប្រើកូនកញ្ច្រែងជ័រ



ការរាប់កូនត្រីពូជដាក់ក្នុងថង់

## ចំនួនកូនត្រីពូជដាក់ចិញ្ចឹមៈ

ចំនួនកូនត្រីពូជដាក់ចិញ្ចឹមគឺអាស្រ័យលើប្រភេទត្រី ។ តារាងខាងក្រោមបង្ហាញពីចំនួនកូនត្រីពូជដែលត្រូវដាក់ចិញ្ចឹមៈ

| ប្រភេទកូនត្រីពូជ | ចំនួនកូនត្រីដាក់ចិញ្ចឹម ក្បាល/ម$^{២}$ | ពីព្រោះ |
|---|---|---|
| ត្រីប្រា | អាចដាក់ពី ១០-១៥ ក្បាល (ទឹកស្រះ) | ធន់ជាមួយទឹកស្រះ |
| ប្រភេទត្រីចិញ្ចឹមចំរុះៈ<br>○ត្រីកាបស<br>○ត្រីកាបឥណ្ឌា<br>○ត្រីកាបសាមញ្ញ<br>○ត្រីឆ្ពិន<br>○និងត្រីប្រា | ៣-៦ ក្បាល | ត្រូវការកន្លែងទូលាយ និងបរិមាណ អុកស៊ីសែនគ្រប់គ្រាន់ ។ |
| | ចំពោះត្រីកាបសាមញ្ញ អាចដាក់ចិញ្ចឹមត្រឹមតែ ៥ ភាគរយនៃចំនួនត្រីដាក់ចិញ្ចឹមសរុប ។ | ប្រសិនបើលើសពីចំនួននេះ វាអាចធ្វើឱ្យទឹកស្រះកករ ឬកខ្វក់ ដោយសារត្រីប្រភេទនេះវាឈូស ដីបាតស្រះ និង ទំនប់ស្រះ ។ |
| ត្រីទីឡាព្យា | ១-២ក្បាល | អាចបន្តពូជក្នុងស្រះ |

## របៀបលែងកូនត្រី

- ពេលវេលាល្អសម្រាប់លែងកូនត្រី គឺពេលដែលមានអាកាសធាតុត្រជាក់ ជាពិសេសចាប់ពីម៉ោង ០៩:០០ ទៅម៉ោង ១១:០០ព្រឹក ។
- ត្រូវត្រាំថង់កូនត្រីពូជក្នុងទឹកស្រះដែលត្រូវលែងរយៈពេលយ៉ាងតិចពី ១០-១៥ នាទី មុនពេលលែងកូនត្រី ធ្វើដូចនេះដើម្បីឱ្យសីតុណ្ហភាពទឹកក្នុងថង់កូនត្រីប្រហាក់ប្រហែលជាមួយសីតុណ្ហភាពទឹកស្រះចិញ្ចឹមត្រី ។
- ក្រោយមក ត្រួតពិនិត្យទឹកក្នុងថង់ដាក់កូនត្រីដោយបើកមាត់ថង ហើយដាក់ដៃចូលដល់ទឹកក្នុងថង់ និង ដាក់ដៃចូលក្នុងទឹកស្រះ ប្រសិនបើសីតុណ្ហភាពទឹកក្នុងថង់ក្តៅជាងទឹកស្រះ ត្រូវបាចទឹកស្រះបញ្ចូលក្នុងថង់ដាក់កូនត្រីរហូតដល់សីតុណ្ហភាពទឹកក្នុងថង់ និងទឹកក្នុងស្រះមានភាពប្រហាក់ប្រហែលគ្នា ពេលនោះយើងអាចលែងកូនត្រីចូលក្នុងទឹកស្រះបាន ។
- ក្នុងករណីសីតុណ្ហភាពទឹកស្រះខ្ពស់ជាង យើងត្រូវកូរទឹកស្រទាប់កណ្តាលស្រះឡើងដើម្បីបន្ថយសីតុណ្ហភាពទឹកស្រះមុនពេលលែងកូនត្រី ។



ត្រាំថង់កូនត្រី ពី ១០-១៥ នាទី



បាចទឹកស្រះចូលក្នុងថង់កូនត្រី



សកម្មភាពលែងកូនត្រីថ្នមៗ

## វិធីសាស្ត្រដាក់ជីបន្ថែមក្នុងពេលចិញ្ចឹមត្រី

បន្ទាប់ពីលែងកូនត្រីពូជចូលក្នុងស្រះចិញ្ចឹមបានប្រមាណ ១០-១៥ ថ្ងៃ រួចមកត្រូវពិនិត្យមើលទឹកស្រះ ប្រសិនបើទឹកស្រះលែងមានពណ៌បៃតងនោះជាពេលដែលយើងត្រូវដាក់ជីបន្ថែមចូលក្នុងទឹកស្រះ។ វិធីសាស្ត្រក្នុងការដាក់ជីបន្ថែមមានដូចជា:

### ជីករណ្តៅជាប់មាត់ស្រះ

- រណ្តៅជីមានរាងជាបួនជ្រុងទ្រវែងដែលមានបណ្តោយប្រវែងប្រមាណ ១ ម៉ែត្រ និងទទឹងប្រមាណ ០.៥ ម៉ែត្រ ហើយជំរៅប្រមាណពី ០.៣-០.៥ ម៉ែត្រ (មើលរូបខាងក្រោម)។
- ក្នុងរណ្តៅជីមានជីលាមកសត្វ ដូចជាជីលាមកគោ ជីលាមកជ្រូក ជីលាមកក្របី ជីលាមកមាន់ និងរុក្ខជាតិបៃតងមាន ទន្ទ្រានខែត្រ និងកាកសំណល់បន្លែផ្សេងៗលាយបញ្ចូលគ្នា និងបន្ថែមទឹកជារៀងរាល់ថ្ងៃ។ ទឹកល្បាយជីដែលបានមកអាចហូរចូលទៅក្នុងស្រះជារៀងរាល់ថ្ងៃ។
- ល្បាយជីក្នុងរណ្តៅអាចដូរថ្មីបាននៅពេលដែលអស់ជាតិជី (ពណ៌បៃតង)។



**ការប្រើជីលាមកសត្វ**——មើលនៅទំព័រទី ៨

**ការប្រើជីគីមី**——មើលនៅទំព័រទី ៨

ក្នុងករណីទឹកស្រះឡើងពណ៌បៃតងចាស់ ពណ៌ត្នោត ឬទឹកស្រះមានក្លិនមិនល្អត្រូវបញ្ឈប់ការបង្ហូរទឹកជីចូលក្នុងទឹកស្រះ ឬឈប់ប្រើជីគ្រប់ប្រភេទជាបណ្តោះអាសន្ន។ ការចាប់ផ្តើមប្រើជាថ្មីបានលុះត្រាតែទឹកស្រះលែងមានពណ៌បៃតងចាស់ និងឈប់មានក្លិនមិនល្អ។

# ចំណី និង ការផ្តល់ចំណី

ទោះបីជាត្រីរស់នៅតាមទន្លេ ស្ទឹង បឹងបួរ ក្នុងធម្មជាតិមិនចាំបាច់មានការផ្តល់ចំណីយ៉ាងណាក៏ដោយ ក៏ការចិញ្ចឹមត្រីនៅក្នុងស្រះ តំរូវជាចាំបាច់នូវការផ្តល់ចំណីបន្ថែមដល់ត្រីចិញ្ចឹម។ ការប្រើប្រាស់ចំណីតាមលក្ខណៈបច្ចេកទេស និងមានកំរិតប្រូតេអ៊ីនសមស្រប វាជាកត្តាមួយអំណោយផលល្អដល់ការចិញ្ចឹមត្រី ពីព្រោះវាអាចជួយឱ្យត្រីឆាប់ធំដោយប្រើរយៈពេលខ្លី និងអាចរកបានប្រាក់ចំណេញពីមុខរបរចិញ្ចឹមបាន។

## ចំណី

ចំណីត្រីមានពីរប្រភេទ គឺចំណីធម្មជាតិ និងចំណីផ្សំ:

**ចំណីធម្មជាតិ:** រួមមានសត្វល្អិតប្លង់តុង រុក្ខជាតិប្លង់តុង ពពួកវារីសត្វ និងវារីរុក្ខជាតិដែលរស់នៅស្រទាប់បាត។ ពពួកចំណីទាំងនេះអាចកើតឡើងតាមរយៈការប្រើប្រាស់ជីនិង មួយទៀតអាចរកបានក្នុងមូលដ្ឋានដូចជា: ពងទឹក ដង្កូវទឹក ចកបាយទា ព្រលិតកណ្តៀរ និងជន្លេន។ ចំពោះចំណីធម្មជាតិទាំងនេះ មិនគ្រប់គ្រាន់សម្រាប់មុខរបបរចិញ្ចឹមត្រីនោះទេ។



**ចំណីផ្សំ៖** សមាសធាតុអាចផ្សំជាចំណីត្រីបានរួមមាន កន្ទក់ ចុងអង្ករ ពោត សណ្តែកសៀង ត្រីនុយ ម្សៅត្រី កាកសំណល់បន្លែ និងកាកសំណល់ទីសត្តឃាត ។

ចំណីផ្សំអាចផ្សំពីកន្ទក់ ៥០% ចុងអង្ករ ១០% សណ្តែកសៀង ១០% និងត្រីនុយ ៣០% ។ កាកសំណល់បន្លែ កាកសំណល់ផ្ទះបាយ និង ទីសត្តឃាត អាចប្រើជាចំណីបន្ថែម ។

ចំណីផ្សំគួរកូរឱ្យបានសព្វក្នុងពេលចំអិន ហើយទុកឱ្យត្រជាក់មុនពេលផ្តល់ឱ្យត្រីស៊ី ។ សម្រាប់ចំណីដែលមានបរិមាណច្រើនត្រូវប្រើម៉ាស៊ីនសម្រាប់កូរចំណី (មើលរូបភាពក្នុងទំព័រទី២១ ជាឧទាហរណ៍) ។

ចំណីគ្រាប់ (ចំណីបាវ ឬ ចំណីរោងចក្រ) មានច្រើនប្រភេទហើយអាចរកទិញបាន ។ ចំពោះការប្រើប្រាស់ចំណីប្រភេទនេះ គឺមានបង្ហាញប្រាប់ពីរបៀបប្រើនៅលើសំបកបាវនៃផលិតផលនីមួយៗ ។

## ការផ្តល់ចំណី

- ត្រូវកំណត់កន្លែងសម្រាប់ឱ្យចំណីត្រី និងកំណត់ពេលវេលាឱ្យបានទៀងទាត់ជារៀងរាល់ថ្ងៃក្នុងការឱ្យចំណីត្រី ព្រោះត្រីអាចចាំកន្លែងសម្រាប់ស៊ីចំណី ។
- ពេលវេលាល្អសម្រាប់ឱ្យចំណីត្រី គឺពេលព្រឹកចាប់ពីម៉ោង ០៩:០០-១០:០០ និងពេលល្ងាច ពីម៉ោង ០៤:០០-០៥:០០ ។
- អត្រាចំណីដែលត្រូវផ្តល់ឱ្យត្រី គឺប្រមាណពី ៣-៥% នៃទំងន់ត្រីសរុបក្នុងទឹកស្រះ ។
- ចំណីផ្សំគួរចំអិន និងទុកឱ្យត្រជាក់មុនពេលឱ្យចំណីត្រី ។ ចំណីអាចពូតជាដុំៗប៉ុនកណ្តាប់ដៃ បោះដោយដៃឱ្យត្រីស៊ី ឬដាក់ក្នុងកញ្ច្រែង

ពន្លិចចូលទៅក្នុងទឹកស្រះប្រមាណពី ០.៣-០.៥ម៉ែត្រ។

- ឬប្រើម៉ាស៊ីនសម្រាប់កិនចំណីឱ្យត្រីស៊ីដោយផ្ទាល់ (មើលទំព័រ ២៤)។
- ចកបាយទា ឬកាកសំណល់បន្លែ ត្រូវដាក់ក្នុងស៊ុម (មើលរូបខាងក្រោម)។ ចំពោះចកបាយទា ត្រូវមានការប្រុងប្រយ័ត្ន ព្រោះថាប្រសិនបើប្រមូលយកចកបាយទាពីកន្លែងដែលមានទឹកមិនល្អ ឬ ទឹកស្អុយយកមកឱ្យត្រីស៊ីនោះវាអាចបណ្តាលឱ្យត្រីងាប់។



ស៊ុមដាក់ចកបាយទា និង កាកសំណល់បន្លែ



**ម៉ាស៊ីនកិនចំណីតំលៃប្រមាណពី ២០០-២៥០ ដុល្លាផលិតនៅក្នុងក្នុងស្រុក**

អត្ថប្រយោជន៍នៃការប្រើម៉ាស៊ីនកិនចំណី គឺចំណីអាចកិនទៅជាបំណែកតូចៗ ហើយអាចនៅក្នុងទឹកបានយូមុននឹងរលាយក្នុងទឹក ដូចនេះត្រីអាចស៊ីដុំចំណីទាំងអស់នោះបាន ហើយអាចកាត់បន្ថយភាពកខ្វក់ក្នុងទឹកស្រះដែលបណ្តាលមកពីកាកសំណល់នៃចំណី។



ពេលឱ្យចំណីត្រីដោយដៃ វិធីល្អគឺត្រូវពូតចំណីដូចកូនបាល់មុននឹងទំលាក់ចូលក្នុងទឹកស្រះ។ ទំហំកូនបាល់នៃចំណីគឺអាស្រ័យទៅលើទំហំត្រីចិញ្ចឹម។ ការឱ្យចំណីត្រីដោយដៃ គឺជាឱកាសល្អក្នុងការតាមដានចរិកស៊ីចំណីរបស់ត្រី និងតាមដានជម្ងឺត្រីទៀតផង។



ការផ្តល់ចំណីត្រីដោយដាក់ក្នុងកញ្រ្ចែង គឺជាវិធីសាស្រ្តមួយដ៏ល្អ ជាពិសេសសម្រាប់អាជីវករចិញ្ចឹមត្រីខ្នាតតូច។ ចំណីដាក់ក្នុងកញ្រ្ចែង ហើយពន្លិចចូលទៅក្នុងទឹកដោយប្រើខ្សែចង។ បរិមាណចំណីអាចប្រែប្រួលអាស្រ័យលើបរិមាណចំណីដែលមានសល់ ឬអស់ពីកញ្រ្ចែង។ ម្យ៉ាងទៀតអាចកាត់បន្ថយភាពកខ្វក់នៃទឹកស្រះដែលបណ្តាលមកពីការប្រើចំណីលើសកំរិត។

## ការត្រួតពិនិត្យ និង ការតាមដានស្រះចិញ្ចឹមត្រី

ដើម្បីចិញ្ចឹមត្រីឱ្យបានជោគជ័យ ត្រូវប្រុងប្រយ័ត្នលើកត្តាមួយចំនួនដូចខាងក្រោមៈ

- ស្រះគួរតែមានពន្លឺគ្រប់គ្រាន់។
- ត្រូវរៀបចំស្រះចិញ្ចឹមត្រីតាមលក្ខណៈបច្ចេកទេសមុនពេលលែងកូនត្រីចូលស្រះ។
- ត្រូវដាំស្មៅនៅលើទំនប់ស្រះ ដើម្បីកាត់បន្ថយចំរោះដែលបណ្ដាលឱ្យទឹកស្រះល្អក់។
- ត្រូវមានរនាំង ឬបន្ទះស្បៃមុងដាក់លើទំនប់ស្រះដើម្បីការពារពពួកត្រីកាចចូលក្នុងស្រះ (មើលរូបខាងក្រោម)។



- មិនត្រូវឱ្យមានរុក្ខជាតិដុះក្នុងស្រះចិញ្ចឹមត្រីលើសពី ២០%នៃផ្ទៃស្រះចិញ្ចឹមត្រីទេ។

- ត្រូវត្រួតពិនិត្យទំនប់ស្រះជាប្រចាំក្រែងមានធ្លុះធ្លាយ និងលិចទឹកពេលមានភ្លៀងធំដែលបណ្តាលឱ្យត្រីចិញ្ចឹមចេញពីស្រះអស់។
- ត្រួតពិនិត្យគុណភាពទឹកស្រះ ដើម្បីឱ្យទឹកស្រះមានពណ៌បៃតង (ចំពោះការចិញ្ចឹមត្រីស្រកា) ប្រសិនបើទឹកស្រះលែងមានពណ៌បៃតងនោះត្រូវដាក់ជីបន្ថែមព្រោះថាគុណភាពទឹកពណ៌បៃតង ត្រីមានការលូតលាស់លឿនដោយសារត្រីស៊ីចំណីដែលកើតចេញពីការដាក់ជីទាំងនោះ។
- ត្រូវតាមដាននូវប្រភេទសត្វផ្សេងៗ ដែលបណ្តាលឱ្យមានមហន្តរាយដល់ត្រីចិញ្ចឹម។
- ហាមមិនឱ្យមានសត្វចូលដេក ឬចូលត្រាំក្នុងទឹកស្រះដូចជាសត្វជ្រូក ឬសត្វក្របីជាដើម។
- មិនត្រូវយកស្លឹកត្នោត ឬស្សី ឬបណ្តាស្លឹកផ្សេងៗយកមកត្រាំក្នុងទឹកស្រះទេ ព្រោះវាបណ្តាលឱ្យទឹកស្រះកខ្វក់ហើយបណ្តាលឱ្យត្រីងាប់។
- ប្រសិនបើត្រីមានជម្ងឺ ឬមានត្រីងាប់ក្នុងស្រះត្រូវយកចេញភ្លាម។
- ហាមមិនឱ្យមានថ្នាំពុលហូរចូលក្នុងស្រះចិញ្ចឹមត្រី ឬយកធុងបាញ់ថ្នាំសំលាប់សត្វល្អិតទៅលាងសំអាតក្នុងទឹកស្រះឡើយ។
- ពេលបង្ហូរទឹកចូលក្នុងស្រះ ត្រូវចងស្បៃនឹងបំពង់បង្ហូរដើម្បីការពារត្រីកាចចូលក្នុងស្រះ។
- ប្រសិនបើការចិញ្ចឹមត្រីពឹងផ្អែកតែលើទឹកភ្លៀង នោះត្រូវរៀបចំស្រះដាក់ត្រីចិញ្ចឹមឱ្យបានទាន់រដូវភ្លៀង។

## ការយល់ច្រឡំលើមុខរបរចិញ្ចឹមត្រី

១- **"ខ្ញុំមិនមានពេលរៀបចំស្រះមុនពេលលែងកូនត្រីទេ "** ប្រសិនបើមិនបានសំអាតស្រះ និងរៀបចំស្រះឱ្យបានល្អទេ ត្រីកាចដែលមាននៅក្នុងស្រះហើយជាស្រេចនោះ វានឹងស៊ីកូនត្រីពូជអស់។ ម្យ៉ាងទៀតកូនត្រីពូជមួយចំនួនអាចគេចចេញតាមរន្ធដែលមានស្រាប់តាមជញ្ជាំងស្រះ នេះហើយជាការខាតបង់ប្រាក់ឥតប្រយោជន៍ ព្រោះថាពេលប្រមូលផលមានត្រីតែមួយចំនួនតូចប៉ុណ្ណោះដែលនៅរស់។

២- **"ប្រសិនបើខ្ញុំដាក់កូនត្រីពូជច្រើន ពេលប្រមូលផលខ្ញុំបានផលច្រើន"** ការទិញកូនត្រីពូជច្រើនដាក់ចិញ្ចឹមលើសពីសេចក្តីត្រូវការ វាជាការខាតបង់ថវិកាឥតប្រយោជន៍ ព្រោះថាចំនួនត្រីដាក់ចិញ្ចឹមច្រើន ប៉ុន្តែចំណី និងទំហំស្រះមិនសមស្របធ្វើឱ្យត្រីមានការលូតលាស់មិនបានល្អ ម្យ៉ាងទៀតទឹកស្រះនឹងកខ្វក់ (ចំលងមេរោគ) ហើយត្រីមានការលូតលាស់យឺតបំផុត។

៣- **"ត្រីធម្មជាតិមិនបាច់ឱ្យចំណី ដូច្នេះខ្ញុំមិនចាំបាច់ឱ្យចំណីត្រីចិញ្ចឹមខ្ញុំទេ"** នៅក្នុងធម្មជាតិត្រីត្រូវការពេលវេលាសម្រាប់ការលូតលាស់ ប៉ុន្តែនៅក្នុងមុខរបរចិញ្ចឹមត្រី ប្រសិនបើប្រើរយៈពេលយូរនោះវានឹងមិនអាចរកប្រាក់ចំណេញបានទេ។ ដូចនេះ ប្រសិនបើប្រើចំណីដែលមានគុណភាព និងបរិមាណគ្រប់គ្រាន់ត្រីអាចលូតលាស់បានលឿនហើយប្រើរយៈពេលខ្លី អ្នកនឹងទទួលបានផលច្រើន និងប្រាក់ចំណូលទៀតផង។

៤- **"ពេលណាត្រីឡើងមកស្រទាប់លើនៃទឹកស្រះ នោះបានន័យថាត្រីត្រូវការ**

**ចំណី ហើយត្រូវតែឱ្យចំណី "** ត្រីឡើងមកស្រទាប់លើដើម្បីដកដង្ហើមមិនមែនមានន័យថា ត្រីត្រូវការចំណីនោះទេ។ ការឱ្យចំណីគួរតែកំណត់កន្លែង និងទៀងពេលវេលា មិនមែនផ្លាស់ប្តូរគ្រប់ទីកន្លែងនោះទេ។ ចំណីត្រូវតែប្រែប្រួលតាមតំរូវការរបស់ត្រី (៣-៥ ភាគរយ) ប្រសិនបើឱ្យចំណីក្នុងបរិមាណច្រើនលើសលុបធ្វើឱ្យទឹកស្រះកខ្វក់ និង ត្រីអាចងាប់ច្រើន។

៥-**"វាជាការល្អដែលយើងអាចដាំពពួកវារីរុក្ខជាតិក្នុងស្រះចិញ្ចឹមត្រីព្រោះវាអាចជាចំណីត្រី"** ពពួកវារីរុក្ខជាតិអាចឱ្យមានតិចជាង ២០ ភាគរយនៃទំហំស្រះ ព្រោះថាប្រសិនបើលើសពីនេះត្រីអាចងាប់ ឬជួបនូវកង្វះអុកស៊ីសែនដែលជាកត្តាមួយធ្វើឱ្យត្រីមានការលូតលាស់យឺត។

៦-**"កូនត្រីពូជពីធម្មជាតិអាចមានអត្រារស់ និងអត្រាលូតលាស់បានល្អជាងកូនត្រីពូជយកមកពីស្ថានីយ៍ "** ជាក់ស្តែងកូនត្រីពូជដែលបានពីស្ថានីយ៍បង្កាត់ភ្ញាស់ គឺវាល្អជាង ព្រោះថាពពួកនេះបានបន្សាំជាមួយទឹកស្រះ និងចំណីហើយជាស្រេច ម្យ៉ាងទៀតកូនត្រីពូជទាំងនោះមានទំហំប្រហាក់ប្រហែលគ្នាហើយមានការលូតលាស់លឿន។ ចំពោះការចាប់កូនត្រីពូជពីធម្មជាតិនឹងធ្វើឱ្យធនធានជលផលមានការវិនាសយ៉ាងឆាប់រហ័ស ហើយវាជាសកម្មភាពខុសច្បាប់ទៀតផង។

# ការប្រមូលផលត្រី

## ការប្រមូលផលត្រីរំលោះ

- រយៈពេល ០៣ ខែ បន្ទាប់ពីដាក់ត្រីចិញ្ចឹម យើងអាចចាប់ត្រីធ្វើជាម្ហូបអាហារប្រចាំថ្ងៃបាន ហើយត្រីដែលនៅសល់ក្នុងស្រះអាចមានការលូតលាស់បានយ៉ាងឆាប់រហ័ស ។
- ឧបករណ៍សម្រាប់ចាប់ត្រីរួមមាន សន្ទូច មង សំណាញ់ និងកន្រ្តងចំណើ (ដោយលើកថ្មមៗ) ។

## ការប្រមូលផលសរុប

- ការប្រមូលផលត្រីអាចប្រព្រឹត្តទៅបាននៅពេលដែលតំលៃត្រីនៅលើទីផ្សារឡើងថ្លៃ និងនូវពេលដែលទឹកស្រះជិតអស់ទឹក ។
- ត្រីចិញ្ចឹមអាចប្រមូលផលបាននៅពេលមានទីផ្សារ (អ្នកទិញ) ។
- មុនពេលបូមទឹកស្រះចាប់ត្រីត្រូវរៀបចំហាប៉ា និងសំណាញ់-អួនឱ្យបានមុន ដើម្បីរក្សាត្រីឱ្យនៅរស់ បន្ទាប់ពីចាប់ត្រីចេញពីស្រះ ព្រោះថាអ្នកទិញត្រីត្រូវការតែប្រភេទត្រីរស់ ។
- ជាវិធីល្អក្នុងការប្រមូលផលត្រីបានស្រួល និងដើម្បីកុំឱ្យត្រីមានរបួស គឺត្រូវបូមទឹក ឬបង្ហូរទឹកស្រះឱ្យនៅតែពាក់កណ្តាលហើយប្រើអួនអូសចាប់ជាការស្រេច ។



ការចាប់ត្រីចិញ្ចឹមសម្រាប់ធ្វើជាម្ហូបអាហារដោយប្រើមង



ការប្រមូលផលត្រីចិញ្ចឹមដោយប្រើអួនអូស

# ទីផ្សារ និងផ្សារលក់ផលិតផល

## ទីផ្សារក្នុងឃុំ

អ្នកចិញ្ចឹមត្រីខ្នាតតូច ទីផ្សារក្នុងមូលដ្ឋាន គឺជាកន្លែងដ៏ល្អសម្រាប់លក់ផលិតផលដែលផលិតបាន។ កាលមុនចាប់ផ្តើមមុខរបរចិញ្ចឹមត្រី ផលត្រីដែលចាប់ពីធម្មជាតិ គឺជាកត្តាសំខាន់ក្នុងតំបន់របស់អស់លោកអ្នក។ នៅរដូវប្រាំងផលិតផលត្រីចិញ្ចឹមមានតំលៃខ្ពស់ ដូច្នេះសូមលោកអ្នកគួរមានគម្រោងផែនការចិញ្ចឹម និងប្រមូលផលឱ្យទាន់នៅរដូវនេះ។ នៅពេលរដូវប្រមូលផលត្រីហើយអ្នករង់ចាំតែឈ្មួញទិញត្រីមកទិញ នោះមិនមែនជាការល្អសម្រាប់មុខរបរចិញ្ចឹមត្រីនោះទេ ព្រោះលក់មិនបានថ្លៃ ដូច្នេះអ្នកចិញ្ចឹមត្រីត្រូវតែស្វែងរកតំលៃទីផ្សារឱ្យបានមុនពេលលក់ត្រីទើបជាការប្រសើរ ព្រោះអាចលក់បានថ្លៃខ្ពស់។

## ទីផ្សារក្នុងបណ្តាខេត្ត

ប្រសិនបើចិញ្ចឹមត្រីសម្រាប់ផ្គត់ផ្គង់ដល់ទីផ្សារក្នុងខេត្ត អ្នកត្រូវតែមានគម្រោងផលិត និងផ្គត់ផ្គង់ឱ្យបានទៀតទាត់ បើមិនដូច្នោះទេនោះនឹងធ្វើឱ្យមុខរបរចិញ្ចឹមត្រីជួបនូវបញ្ហា។ ដូច្នោះដើម្បីទទួលបានជោគជ័យលើមុខរបរនេះត្រូវតែមានប្រភពទឹកគ្រប់គ្រាន់ ពោលគឺមិនពឹងផ្អែកលើទឹកភ្លៀងទាំងស្រុងនោះទេ។ ចំពោះតំរូវការត្រីនៅទីផ្សារក្នុងខេត្តអាចមានតំរូវការផ្សេងៗគ្នា ហេតុនេះអ្នកគួរតែសាកសួរពតិមានជាមួយអាជីវករទិញត្រីឱ្យបានមុន ពេលអ្នកចាប់ផ្តើមមុខរបរចិញ្ចឹមត្រី។

## ទីផ្សារក្នុងខេត្តកណ្តាល ខេត្តសៀមរាប និង ទីក្រុងភ្នំពេញ

ដើម្បីឱ្យផលិតផលត្រីចិញ្ចឹមរបស់លោកអ្នកអាចលក់បាននៅលើទីផ្សារទាំង

នេះ អ្នកត្រូវតែផ្តោតលើចំនុចសំខាន់ៗមួយចំនួនដូចខាងក្រោម :

- សាច់ត្រីគួរតែមានពណ៌ស (ចំពោះត្រីប្រា) ។
- រសជាតិ និងក្លិនរបស់ត្រីត្រូវតែបំពេញទៅតាមតំរូវការរបស់អ្នកប្រើប្រាស់ ។
- ត្រូវផ្គត់ផ្គង់ត្រីដែលមានគុណភាពឱ្យបានទៀងទាត់ទៅលើទីផ្សារ ។

ដូច្នេះអ្នកគួរតែសាកសួរអ្នកទិញត្រី ឬឈ្មួញកណ្តាលឱ្យបានដឹងថាអ្វីជាតំរូវការក្នុងទីផ្សារគោលដៅ មុនពេលអ្នកចាប់ផ្តើមមុខរបរចិញ្ចឹមត្រីរបស់លោកអ្នក ។

**សំគាល់:** ជាបទពិសោធន៍ជាមួយអ្នកចិញ្ចឹមត្រីបានបង្ហាញថា ពណ៌សំបុរសាច់ត្រីវាអាចបណ្តាលមកពីប្រភេទចំណីដែលផ្តល់ឱ្យត្រីស៊ី ជារួមចំណីផ្សំពីកន្ទក់ និងពោតភាគច្រើនវាបណ្តាលឱ្យសាច់ត្រីមានសំបុរពណ៌លឿងព្រឿង ដែលសាច់ត្រីប្រភេទនេះមិនមែនជាសាច់ត្រីដែលមានគុណភាពល្អតាមតំរូវការទីផ្សារឡើយ ។ ចំពោះការប្រើប្រាស់ប្រភពទឹកល្អ នឹងអាចជួយឱ្យសាច់ត្រីមានរសជាតិឆ្ងាញ់ និងមានក្លិនល្អ ។

## កត្តាប្រុងប្រយ័ត្នលើការងារចិញ្ចឹមត្រី

### ការកត់ត្រាចំណាយ និងចំណូល

ការកត់ត្រាចំណូល និងចំណាយជាប្រចាំលើមុខរបរចិញ្ចឹមត្រី គឺជាកត្តាសំខាន់ ពីព្រោះវាអាចជួយអ្នកឱ្យដឹងពីតំលៃដើមរបស់ផលិតផល ប្រាក់ចំណេញ និងអាច ជាកត្តាមួយសំខាន់សម្រាប់លោកអ្នកពង្រីកលើមុខរបរចិញ្ចឹមត្រីរបស់លោកអ្នក។ កត្តាមួយទៀត ប្រសិនបើលោកអ្នកមានការកត់ត្រាចំណូល-ចំណាយបានល្អ វា អាចជួយឱ្យអ្នកអាចខ្ចីប្រាក់ពីធនាគារ និងពីអ្នកចងការប្រាក់បានទៀតផង ព្រោះ ថាលោកអ្នកមានការយកចិត្តទុកដាក់ខ្ពស់លើមុខរបររបស់លោកអ្នក។

រាល់ការកត់ត្រាចំណាយតាមប្រភេទចំណាយនីមួយៗបានត្រឹមត្រូវ គឺវា ប្រសើរជាងការកត់ត្រាច្របូកច្របល់គ្នា។ ជាឧទាហរណ៍ ពេលដែលលោកអ្នក ចង់ជីកស្រះ ឬពង្រីកស្រះ វាមានសារៈសំខាន់ដែលឱ្យលោកអ្នកបានដឹងពីចំណាយ សរុបនៃការជីកស្រះ ឬរៀបចំស្រះ។ ខាងក្រោមនេះ គឺរបៀបនៃការកត់ត្រា ចំណាយតាមចំណាត់ប្រភេទនីមួយៗ :

**១-ចំណាយសម្រាប់ការរៀបចំស្រះ**

- តំលៃកំលាំងពលកម្ម
- ចំណាយលើការជួលម៉ាស៊ីនបូមទឹកបញ្ចូលស្រះ
- ចំណាយលើប្រេងឥន្ធនៈ
- ចំណាយលើការទិញកំបោរសម្រាប់បាចស្រះ
- ចំណាយលើការទិញជី ដូចជា ជីលាមកសត្វ ឬជីគីមី

**២-ចំណាយលើការទិញកូនត្រីពូជ**

- ថ្លៃកូនត្រីពូជដាក់ចិញ្ចឹម
- ថ្លៃដឹកជញ្ជូនកូនត្រីពូជ
- ថ្លៃកំលាំងពលកម្ម

**៣- ចំណាយលើចំណីត្រី**

- ចំណាយលើវត្ថុធាតុដើមនៃចំណី
- ចង្ក្រាន និង ខ្ទះចំអិនចំណីត្រី
- ម៉ាស៊ីនកិនចំណីត្រី
- ប្រេងសម្រាប់ចំអិន និង កូរចំណីត្រី
- ថ្លៃកំលាំងពលកម្ម

**៤- ចំណាយផ្សេងៗលើការគ្រប់គ្រងគុណភាពទឹកស្រះ និង ការតាមដាន**

- ចំណាយលើការទិញជី
- ចំណាយលើការបូបទឹកចូល និង បូមទឹកចេញ
- ការប្រើប្រាស់ថ្នាំសម្រាប់ព្យាបាលត្រី
- ស្បៃមុងសម្រាប់ការពារត្រីស្រែចូលស្រះ
- ថ្លៃកំលាំងពលកម្ម

កត្តាមួយចំនួនដែលអ្នកត្រូវយកចិត្តទុកដាក់លើការកត់ត្រាចំណូល និង បរិមាណត្រីដែលទទួលបានក្នុងដំណាក់កាលចិញ្ចឹមត្រីមានដូចខាងក្រោម :

- ការលក់កូនត្រី និង លក់ត្រីជាប្រចាំថ្ងៃ (សម្រាប់ការចិញ្ចឹមត្រីទីឡាព្យា)

- ទំងន់ត្រីដែលចាប់ហូបប្រចាំថ្ងៃ និងសម្រាប់ពិធីជប់លៀងផ្សេងៗ ប្រចាំគ្រួសារ ។
- ទំងន់ត្រីដែលឱ្យអ្នកជិតខាង
- ទំងន់ត្រីសម្រាប់ទុកមេពូជ (ចិញ្ចឹមវគ្គក្រោយ)
- ទំងន់ត្រីដែលលក់សរុប

ខាងក្រោមជាទំរង់បែបបទមួយដែលអាចប្រើសម្រាប់ការកត់ត្រាចំណាយលើការងារចិញ្ចឹមត្រី :

ទំហំស្រះ : ______________ ទីតាំង : _________________________

ថ្ងៃដាក់ចិញ្ចឹម : __________ ប្រភេទកូនត្រីពូជ :______ចំនួន : ______

ប្រភេទកូនត្រីពូជ :______ ចំនួនៈ ______

ប្រភេទកូនត្រីពូជ :______ ចំនួន :______

**ការកត់ត្រាចំណាយ**

| ថ្ងៃ ខែ ឆ្នាំ | **ការរៀបចំស្រះ** | | **កូនត្រីដាក់ចិញ្ចឹម** | | **ចំណីត្រី** | | **ការបូមទឹកចេញ-ចូល** | | **ការថ្លឹង ទំងន់ត្រី** |
|---|---|---|---|---|---|---|---|---|---|
| | រាយមុខ | តំលៃ | រាយមុខ | តំលៃ | រាយមុខ | តំលៃ | រាយមុខ | តំលៃ | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

**សំគាល់: ឧបសម្ព័ន្ធ ១ បង្ហាញពីទំរង់បែបបទសម្រាប់អ្នកចិញ្ចឹមត្រីដែលមានលក្ខណៈទ្រង់ទ្រាយមធ្យមប្រើសម្រាប់ធ្វើការវិភាគលើថ្លៃដើម**

## ការចំណាយទុនដើម្បីបង្កើនលើមុខរបរចិញ្ចឹមត្រី

អ្នកចិញ្ចឹមត្រីអាចចាប់ផ្តើមធ្វើមុខរបររបស់ខ្លួនជាមួយនឹងដើមទុនតិចតួចរបស់ខ្លួន ជាមួយស្រះដែលមានទំហំប្រមាណពី ៥០០ ម៉ែត្រការ៉េឡើងទៅដោយផ្តោតជាសំខាន់ទៅលើមូលដ្ឋានគ្រឹះចំនួន ០៤ គឺ:

១- រៀបចំស្រះឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

២- ការគ្រប់គ្រងស្រះចិញ្ចឹមត្រីតាមលក្ខណៈបច្ចេកទេសដូចជា ការតាមដានគុណភាពទឹកស្រះ និង ការថែរក្សាទំនប់ និងរបាំងការពារ (មិនឱ្យត្រីស្រែ ឬពស់ចូល)។

៣- ចំណី និង ការឱ្យចំណី

៤- ការចិញ្ចឹមសម្រាប់ទីផ្សារៈ ប្រភេទត្រីចិញ្ចឹម និងពេលប្រមូលផលឱ្យត្រូវទៅតាមតំរូវការទីផ្សារ។

ជាមធ្យមសម្រាប់ទំហំស្រះ ៥០០ម៉ែត្រការ៉េ អាចប្រមូលផលត្រីបានពី ១-៥ តោន អាស្រ័យទៅលើអ្នកចិញ្ចឹមត្រីដែលបានចំណាយទុន ពេលវេលា និង បច្ចេកទេសគ្រប់គ្រងលើការងារចិញ្ចឹមត្រី។ ប្រសិនបើការចិញ្ចឹមតាមបែបទ្រង់ទ្រាយធំ ទិន្នផលអាចទទួលបានខ្ពស់ជាងនេះ ពោលគឺប្រមាណ ១០ តោន។ ការចិញ្ចឹមតាមបែបទ្រង់ទ្រាយធំ គឺអាចមានរយៈពេលខ្លីជាង។ ដូច្នេះដើម្បីបង្កើនទិន្នផលត្រីចិញ្ចឹមឱ្យបានច្រើន ជាសំខាន់អ្នកចិញ្ចឹមត្រូវមានគំរោងផែនការឱ្យមានការចំណាយបន្ថែមដើម្បីបង្កីនទុនលើមុខរបរ។ នៅពេលដែលមុខរបរចិញ្ចឹមត្រីមានការរីកចំរើន (ប្រាក់ចំណេញ) និង ស្ថិតថេរ អ្នកចិញ្ចឹមត្រីត្រូវតែស្វែងរកទីផ្សារឱ្យបានទូលាយជាបន្ថែមទៀត ។

ចរិតលក្ខណៈរបស់អ្នកចិញ្ចឹមត្រីនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈខុសៗគ្នាៈ

**កំរិតមុខរបរទី១ៈ អាចប្រមូលផលបានពី ១.៥ ទៅ ២ គក្រ ក្នុងមួយម៉ែត្រការ៉េស្រះ**

ការចំណាយទុនជាសំខាន់ ដើម្បីបង្កើនទិន្នផលត្រីដល់កំរិតនេះគឺ

១- ការរៀបចំស្រះមុនពេលលែងកូនត្រី

២- ប្រើចំណីផ្សំ និង ចំណីធម្មជាតិ សត្វប្លង់តុង និងរុក្ខជាតិប្លង់តុងដែលបានមកពីការប្រើជី ។

នៅក្នុងកំរិតមុខរបរទី ១ នេះ អ្វីដែលជាកត្តាសំខាន់គឺ ការរៀបចំស្រះតាមលក្ខណៈបច្ចេកទេសមុនពេលលែងកូនត្រី ការផ្តល់ចំណីឱ្យបានទៀងទាត់ និងចំណីមានគុណភាពល្អ។ ទិន្នផលត្រីចិញ្ចឹមកំរិតនេះ ប្រសិនបើអ្នកចិញ្ចឹមត្រីខ្នាតតូចមានការយកចិត្តទុកដាក់តាមការណែនាំក្នុងការរៀបចំស្រះ តាមលក្ខណៈបច្ចេកទេសមុនពេលលែងកូនត្រី ចំណីមានគុណភាព និងការឱ្យចំណីទៀងទាត់នោះអាចទទួលបានទិន្នផលកំរិតនេះជាមិនខាន។

**កំរិតមុខរបរទី២ៈ អាចប្រមូលផលបានពី ៥ ទៅ ៦គក្រ ក្នុងមួយម៉ែត្រការ៉េស្រះ**

ដើម្បីឱ្យទិន្នផលត្រីប្រមូលបានក្នុងកំរិតទី ២ នេះអ្នកចិញ្ចឹមត្រីត្រូវតែមានការយកចិត្តទុកដាក់ឱ្យបានខ្លាំងទៅលើគុណភាពចំណី អត្រានៃការឱ្យចំណី (ចំនួនដងនៃការឱ្យចំណី) របៀបនៃការឱ្យចំណី និង គុណភាពទឹកស្រះ។ ការចំណាយជាសំខាន់គឺ ចំណីផ្សំ និងមានការយកចិត្តទុកដាក់ពីសមាជិកក្នុងគ្រួសារ ទន្ទឹមនឹងនោះដែរ ក៏ត្រូវតែមានការផ្លាស់ប្តូរទឹកដើម្បីឱ្យទឹកស្រះមានគុណភាពល្អ ព្រោះថា

ការចិញ្ចឹមត្រីតាមបែបនេះគឺ ដាក់ត្រីចិញ្ចឹមក្នុងចំនួនច្រើននាំឱ្យត្រីងាយកើតជម្ងឺ ប្រសិនបើទឹកស្រះមានគុណភាពមិនល្អដោយសារកាកសំណល់នៃចំណី។ ដូច្នេះនៅក្នុងកំរិតមុខរបរទី ២ នេះជាសំខាន់គឺ ចំណីដែលមានគុណភាពល្អ និងទឹកស្រះមានគុណភាពល្អ។ កត្តាដែលត្រូវផ្តោតជាសំខាន់គឺ:

១- ការរៀបចំស្រះតាមបច្ចេកទេសមុនពេលលែងកូនត្រី និង កូនត្រីពូជមានសុខភាពល្អ

២- ចំណី និង ការឱ្យចំណី: ចំណីផ្សំរួមមាន ត្រីនុយ ចំអិនលាយជាមួយកន្ទក់លេខ ១

៣- តាមដានគុណភាពទឹកស្រះ: ទឹកស្រះត្រូវតែប្តូរពី ២-៣ ដងក្នុងពេលចិញ្ចឹមត្រីដើម្បីការពារជម្ងឺត្រី ហើយត្រីមានការលូតលាស់បានលឿន។

៤- ការគ្រប់គ្រងជម្ងឺត្រី: ត្រូវប្រើថ្នាំការពារជម្ងឺត្រី និងព្យាបាលជម្ងឺត្រីពេលត្រីមានជម្ងឺ

## កំរិតមុខរបរទី ៣: អាចប្រមូលផលបានពី ៨ ទៅ ១០គក្រ ក្នុងមួយម៉ែត្រការ៉េស្រះ

ដើម្បីឱ្យទិន្នផលត្រីប្រមូលបានក្នុងកំរិតទី ៣ នេះ អ្នកចិញ្ចឹមត្រីត្រូវតែមានការយកចិត្តទុកដាក់ឱ្យបានខ្លាំង ទៅលើគុណភាពចំណី អត្រានៃការឱ្យចំណី (ចំនួនដងនៃការឱ្យចំណី) របៀបនៃការឱ្យចំណី និង គុណភាពទឹកស្រះ។ ចំនួនត្រីដែលដាក់ចិញ្ចឹមគឺមានចំនួនច្រើន ដូច្នេះត្រូវតាមដានគុណភាពទឹកឱ្យបានម៉ត់ចត់ ពោលគឺអាចប្តូរទឹកស្រះមួយអាទិត្យម្តង (បូមភក់បាតស្រះចេញ)។ បរិមាណចំណីដែលត្រូវផ្តល់ឱ្យត្រូវតែតាមដានឱ្យបានល្អ ជៀសវាងមានកាកសំណល់ចំណីច្រើនក្នុងទឹក

ស្រះ ដែលធ្វើឱ្យទឹកស្រះកខ្វក់យ៉ាងឆាប់រហ័ស។ នៅក្នុងកំរិតមុខរបរទី ៣ នេះ អ្នកចិញ្ចឹមត្រីត្រូវតែចំណាយទុនទៅលើកំលាំងពលកម្មក្នុងការរៀបចំស្រះ ការរៀបចំចំណីផ្សំ និងត្រូវមានម៉ាស៊ីនសំរាប់កិនចំណីផ្សំ (ជាចំណីគ្រាប់ ឬចំណីមូលទ្រវែង) ព្រមទាំងមានប្រភពទឹកគ្រប់គ្រាន់។ កត្តាដែលត្រូវផ្តោតជាសំខាន់គឺ:

១- ការរៀបចំស្រះតាមបច្ចេកទេសមុនពេលលែងកូនត្រី និងកូនត្រីពូជត្រូវមានសុខភាពល្អ

២- ប្រើម៉ាស៊ីនកិនចំណីគ្រាប់ ឬរាងជាទ្រវែង ឬចំណីសំរេច(ចំណីនាំចូល)

៣- ចំណីត្រូវតែមានកំរិតប្រូតេអ៊ីនខ្ពស់

៤- គុណភាពទឹកស្រះ: ត្រូវប្តូរទឹកពី ២០-៣០ ភាគរយនៃទឹកស្រះជារៀងរាល់មួយអាទិត្យម្តង

៥- ការគ្រប់គ្រងជម្ងឺត្រីៈ ត្រូវប្រើថ្នាំការពារជម្ងឺត្រី និងព្យាបាលជម្ងឺត្រីពេលត្រីមានជម្ងឺ

## ករណីជោគជ័យលើមុខរបរចិញ្ចឹមត្រី

### ការទទួលជោគជ័យលើមុខរបរចិញ្ចឹមត្រីខ្នាតតូច

មុខរបរចិញ្ចឹមត្រីខ្នាតតូចអាចទទួលបានផល ដោយគ្រាន់តែពង្រឹងលើផ្នែកបច្ចេកទេសចិញ្ចឹម និងការអនុវត្តបានត្រឹមត្រូវតាមមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងស្រះចិញ្ចឹម និងការឱ្យចំណីត្រី។ ខ្វះការរៀបចំស្រះចិញ្ចឹមត្រីមុនពេលលែងកូនត្រីធ្វើឱ្យមានការថយចុះនៃចំនួនត្រីក្នុងស្រះ ដោយសារតែពពួកត្រីកាចដែលមានក្នុងស្រះស៊ីកូនត្រីពូជ ការឱ្យចំណីមិនគ្រប់គ្រាន់ និងក្នុងស្រះមានពពួករុក្ខជាតិច្រើនលើសលប់ទាំងអស់នេះ គឺកើតឡើងជាធម្មតាចំពោះអ្នកចិញ្ចឹមត្រីខ្នាតតូច។ ជាលទ្ធផលអ្នកចិញ្ចឹមត្រីខ្នាតតូចអាចប្រមូលផលត្រីបានតិចតួចពីស្រះចិញ្ចឹមត្រីរបស់ខ្លួន។ អ្នកចិញ្ចឹមត្រីជាច្រើនក្នុងគម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមនៅកម្ពុជា អាចប្រមូលផលត្រីបានទ្វេដងក្នុងមួយឆ្នាំបន្ទាប់ពីពួកគាត់បានយល់ និង អនុវត្តតាមបច្ចេកទេសចិញ្ចឹមត្រី ដែលផលិតផលរបស់ពួកគាត់អាចប្រើសម្រាប់ផ្គត់ផ្គង់អាហារប្រចាំគ្រួសារ និង សម្រាប់លក់ឱ្យទីផ្សារក្នុងភូមិទៀតផង។ កំណើនប្រាក់ចំណេញដែលទទួលបានអ្នកចិញ្ចឹមបានប្រើប្រាស់សម្រាប់ពង្រីកទិន្នផលរបស់ពួកគេតទៅទៀត។

### ករណីទី១: លោក អាង ចំរើន នៅឃុំជាខ្លាង ស្រុកព្រៃវែង ខេត្តព្រៃវែង

លោក អាង ចំរើន មានស្រះទំហំ ៣៧៥ ម៉ែត្រការ៉េ។ មុនគាត់ចូលជាមួយគម្រោង អេម អេស អេម អ៊ី គាត់អាចប្រមូលផលត្រីបានត្រឹមតែ ២០០ គក្រ



ជារៀងរាល់ឆ្នាំពីស្រះចិញ្ចឹមត្រីរបស់គាត់។ បន្ទាប់ពីគាត់បានអនុវត្តតាមបច្ចេកទេសចិញ្ចឹមត្រី គាត់អាចបង្កើនផលត្រីរបស់គាត់រហូត ដល់ ១-២ គក្រក្នុងមួយម៉ែត្រការ៉េនៃស្រះចិញ្ចឹមត្រី។

បច្ចុប្បន្ននេះ គាត់អាចប្រមូលផលបានប្រមាណ ៦០០ គក្រ ក្នុងមួយឆ្នាំដែលជាលទ្ធផលមានការកើនឡើងប្រមាណ ២០០ ភាគរយ។ ផលត្រីមួយចំនួន លោក អាង ចំរើន ប្រើប្រាស់សម្រាប់ម្ហូបអាហារប្រចាំថ្ងៃរបស់គ្រួសារគាត់ មួយចំណែកទៀតសម្រាប់លក់ឱ្យអ្នកទិញត្រីក្នុងភូមិរបស់គាត់ តំលៃដែលគាត់លក់បានប្រមាណ ៨០០០ រៀល ក្នុង ១គីឡូក្រាម។

លោក អាង ចំរើន បានមានប្រសាសន៍ថា ទិន្នផលដែលគាត់ទទួលបានដូចនេះដោយសារគាត់អនុវត្តទៅតាមបច្ចេកទេសមួយចំនួនដូចខាងក្រោមៈ

- ការប្រើប្រាស់ប្រភពទឹកៈ បូមទឹកអណ្តូង និងទឹកភ្លៀងសម្រាប់ស្រះចិញ្ចឹមត្រីរបស់គាត់
- ចំណី និង ការឱ្យចំណីៈ គាត់បានផ្តល់ចំណីឱ្យត្រីរបស់គាត់ក្នុងមួយថ្ងៃ ១-២ ដង ដោយប្រើៈ
  - ចំណីផ្សំៈ លាយជាមួយកន្ទក់ និង កាកសំណល់បន្លែ។ ចំអិនមុនពេលផ្តល់ឱ្យត្រីស៊ី

- ចំណីធម្មជាតិៈ សត្វប្លង់តុង និង រុក្ខជាតិប្លង់តុងបានដោយសារ
  -ជីលាមកសត្វ មានជីអាចម៍មាន់ និង ជីអាចម៍គោ-ក្របី
  -ជីគីមី មានជី អ៊ុយរ៉េ និង ជី ដេ អា ប៉េ

- ចំនួនត្រីដាក់ចិញ្ចឹមៈ ០៦ក្បាលក្នុងមួយម៉ែត្រការ៉េ
- ការគ្រប់គ្រងៈ បញ្ចូលទឹកបន្ថែមពេលរដូវប្រាំង ការពារត្រីស្រែចូលក្នុងស្រះ និងសង់ទំនប់ដើម្បីការពារសារធាតុពុលហូរចូលក្នុងទឹកស្រះចិញ្ចឹមត្រី។

## ករណីទី២ៈ លោក កែវ ឡា នៅឃុំគាំប្រជីសស្ពាន ស្រុកព្រៃវែង ខេត្តព្រៃវែង



មុនពេលទទួលនូវការជួយគាំទ្រពី គម្រោង អេម អេស អេម អ៊ី លោក កែវ ឡា អាចប្រមូលផលត្រីចិញ្ចឹមបាន តែម្តងក្នុងមួយឆ្នាំ ហើយការចិញ្ចឹមរបស់គាត់មានរយៈពេលយូរ ប៉ុន្តែបន្ទាប់ពីគាត់អនុវត្តបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសចិញ្ចឹមត្រី គាត់អាចចិញ្ចឹមត្រីទីឡាព្យាបានពេញមួយឆ្នាំ សម្រាប់ជាអាហារប្រចាំគ្រួសាររបស់គាត់ និងសម្រាប់លក់ឱ្យអ្នកនៅក្នុងភូមិ ឃុំរបស់គាត់។ កាលពីឆ្នាំទៅ លោក ឡា ប្រមូលផលត្រីបាន ១៨០០ គក្រ សម្រាប់

ស្រះទំហំ ៣០០ ម៉ែត្រការ៉េ ក្នុងនោះ គាត់អាចលក់បាន ១២០០ គក្រ សម្រាប់ទីផ្សារក្នុងភូមិ ឃុំ និងប្រមាណ ៦០០ គក្រ គាត់បានប្រើប្រាស់ជាអាហារប្រចាំគ្រួសារគាត់ ។ អ្វីដែលលោក **ឡា** អនុវត្តបានទទួលជោគជ័យលើការងារបច្ចេកទេសចិញ្ចឹមត្រី និង ទទួលបានផលចំណេញពីមុខរបររបស់គាត់ គាត់បានពង្រីកទំហំស្រះចាស់របស់គាត់រហូតដល់ទំហំ ៩០០ ម៉ែត្រការ៉េ (មុន ទំហំ ៣០០ ម៉ែត្រការ៉េ) និងបានជីកស្រះថ្មីចំនួន ០២ ទៀត ដែលស្រះនីមួយៗមានទំហំប្រមាណ ៦០០ ម៉ែត្រការ៉េក្នុងឆ្នាំនេះ ។ ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ ២០០៨ នេះ លោក **ឡា** បានប្រមូលផលត្រីបានប្រមាណ ១ តោន ក្នុងនោះគាត់លក់បានប្រមាណ ៩០០ គក្រ សម្រាប់ទីផ្សារក្នុងភូមិរបស់គាត់ ។ ដោយសារតែគុណភាពផលិតផលរបស់គាត់ល្អ តំលៃត្រីមានការកើនឡើងពី ៧០០០ទៅ១០០០០ រៀល ក្នុងមួយគីឡូក្រាម ក្នុងឆ្នាំ ២០០៨ នេះ ក្នុងខណៈនោះដែរក៏មានអ្នកទិញត្រីជាច្រើនបានមកទាក់ទងដើម្បីទិញផលិតផលត្រីពីគាត់ ។ លោក **ឡា** បានមានប្រសាសន៍ថា ឆ្នាំនេះលោកនឹងអាចទទួលផលបានទ្វេដងសម្រាប់ជាម្ហូមអាហារប្រចាំគ្រួសាររបស់គាត់ និងសម្រាប់លក់នៅលើទីផ្សារ ហើយគាត់ក៏អាចទទួលបានប្រាក់កំរៃពីការលក់កូនត្រីពូជផងដែរ (កូនត្រីទីឡាព្យា) ។

លោក **ឡា** បានចែករំលែកនូវបទពិសោធន៍របស់គាត់ដែលបានទទួលពីគម្រោង អេម អេស អេម អ៊ី លើការងារចិញ្ចឹមត្រីដូចខាងក្រោម:

- ប្រភពទឹក: ប្រើម៉ាស៊ីនសម្រាប់បូមទឹកអណ្តូង និង បានពីទឹកភ្លៀង
- ចំណី និងការឱ្យចំណីបានត្រឹមត្រូវ និងទៀងទាត់តាមបច្ចេកទេស
- កាកសំណល់ផ្ទះបាយត្រូវបានប្រើជាចំណីត្រី

- កន្ទក់ ម្សៅត្រី និងត្រកួន ត្រូវបានផ្សំជាចំណីបន្ថែមដោយផ្តល់ឱ្យប្រមាណ ១-២ ដងក្នុងមួយថ្ងៃ
- ប្រើជីដើម្បីបង្កើនចំណីធម្មជាតិដូចជា សត្វបួងតុង និង រុក្ខជាតិបួងតុង
- ប្រើចំណីសំរេច ដើម្បីបំពេញបន្ថែមចំណីផ្សំ
- ការគ្រប់គ្រងស្រះចិញ្ចឹមត្រីៈ ត្រូវយកចិត្តទុកដាក់លើការត្រួតពិនិត្យគុណភាពទឹកស្រះ និងការការពារកុំឱ្យត្រីស្រែចូលក្នុងស្រះចិញ្ចឹមត្រី។

## ការទទួលជោគជ័យលើមុខរបរចិញ្ចឹមត្រីខ្នាតមធ្យម

អ្នកចិញ្ចឹមត្រីខ្នាតមធ្យមមានស្រះចិញ្ចឹមត្រីទំហំប្រមាណ ១០០០ ម៉ែត្រការ៉េ និងអាចធំជាងនេះឡើងទៅ ហើយការចិញ្ចឹមអាចមិនបានផលល្អ ប្រសិនបើអ្នកចិញ្ចឹមត្រីមិនបានអនុវត្តត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ព្រោះថាការដាក់ត្រីចិញ្ចឹមក្នុងចំនួនច្រើន ឬការឱ្យចំណីហួសកំរិត គឺជាបញ្ហាសម្រាប់អ្នកចិញ្ចឹមត្រីខ្នាតមធ្យមនេះ។ ប្រសិនបើអ្នកចិញ្ចឹមមានការអនុវត្តតាមលក្ខ័ខ័ណ្ឌបច្ចេកទេសបានល្អ នោះគេអាចប្រមូលផលត្រីបានប្រមាណពី ៨-១០ តោន ក្នុងរយៈពេល ០៨ ខែ (មួយរដូវចិញ្ចឹម)។

ដោយយោងទៅតាមអ្វីដែលអ្នកចិញ្ចឹមត្រីខ្នាតមធ្យមបានរៀនសូត្រពីគម្រោង អេម អេស អេម អ៊ី ឃើញថា អ្នកចិញ្ចឹមត្រីខ្នាតមធ្យមភាគច្រើនបានចំណាយទុនវិនិយោគទៅលើម៉ាស៊ីនកិន និងកូរចំណីត្រី ហើយនឹងម៉ាស៊ីនកិនចំណីជាគ្រាប់ ឬជារាងទ្រវែង។ ឧបករណ៍ទាំងនេះអាចជួយសំរួលដល់ការផលិតចំណីផ្សំក្នុងបរិមាណដ៏ច្រើន។ ចំណីកិនជាគ្រាប់ ឬ ជារាងទ្រវែងអាចចំណេញពេលវេលា និងត្រីងាយស្រួលស៊ីចំណី និងមិនធ្វើអោយទឹកស្រះត្រីស្អុយ (កខ្វក់)។

## ករណីទី៣: លោក សុខ ស៊ីម នៅឃុំកំពង់ព្រះ ស្រុកបាធាយ ខេត្តកំពង់ចាម

លោក សុខ ស៊ីម មានស្រះទំហំ ១០០០ ម៉ែត្រការ៉េ គាត់ចិញ្ចឹមត្រីប្រា។ ជាច្រើនឆ្នាំកន្លងមក គាត់ចិញ្ចឹមត្រីបានតែ ៤ គក្រ ក្នុងមួយម៉ែត្រការ៉េស្រះ ហើយប្រើរយៈពេលវែងគឺ ១៦-១៨ ខែ។ គាត់បានលក់ត្រីប្រមាណ ១-២ តោន ទៅឱ្យអ្នកទិញត្រីក្នុងមូលដ្ឋាន។ បន្ទាប់ពីគាត់បានអនុវត្តតាមបច្ចេកទេសចិញ្ចឹមត្រី គាត់



អាចបង្កើនទិន្នផលត្រីបានរហូតដល់ ៦-៧ គក្រ ក្នុងមួយម៉ែត្រការ៉េស្រះ ហើយប្រើរយៈពេលតែ ៦-៨ ខែ តែប៉ុណ្ណោះ។ សព្វថ្ងៃនេះ លោក សុខ ស៊ីម អាចចិញ្ចឹមត្រីបាន ០២ ដង ក្នុងមួយឆ្នាំ (ឬ ១៦ ខែ)។ កាលពីឆ្នាំមុន លោក សុខ ស៊ីម អាចប្រមូលផលបាន ៧ តោន ពីស្រះរបស់គាត់។

គម្រោង អេម អេស អេម អ៊ី បានជួយលោក សុខ ស៊ីម គិតអំពីទីផ្សាររបស់គាត់ផងដែរ ព្រោះថាប្រសិនបើគាត់នៅតែរង់ចាំអ្នកទិញត្រីដដែលៗ (ម៉ូយចាស់) គាត់នឹងអាចជួបការលំបាកនៅពេលដែលទិន្នផលត្រីរបស់គាត់ មានការកើនឡើង ពេលនោះផលិតផលរបស់គាត់នឹងចុះថ្លៃ។ លោក សុខ ស៊ីម បានទាក់ទងជាមួយអ្នកទិញត្រីដ៏ធំដែលអាចប្រមូលទិញត្រីក្នុងចំនួនច្រើន ប៉ុន្តែគ្រាន់តែមានលក្ខខណ្ឌត្រីត្រូវមានគុណភាពល្អ។ លោក សុខ ស៊ីម បានកែប្រែគុណភាពផលិតផលរបស់គាត់ទៅតាមតំរូវការទីផ្សារ ដើម្បីទាក់ទាញដល់អ្នកទិញត្រី។

ចាប់តាំងពីអ្នកទិញត្រីមានជំនឿលើលោក សុខ ស៊ីម ដែលគាត់អាចចិញ្ចឹមត្រីប្រាបានគុណភាពល្អ អ្នកទិញត្រីបានមានបំណងធ្វើកិច្ចសន្យាទិញត្រីពីគាត់តាមតំលៃទីផ្សារ។ ខាងក្រោមនេះជាបទពិសោធន៍ ដែលលោក សុខ ស៊ីម បានអនុវត្តៈ

- រៀបចំស្រះឱ្យប្រសើរឡើង មុនពេលលែងកូនត្រី
- កែប្រែគុណភាពទឹកស្រះ: ប្រើម៉ាស៊ីនបូមទឹកអណ្តូង និងប្រើទឹកភ្លៀង
- ប្តូរទឹកស្រះ (បូមទឹកស្រះចេញ និងបញ្ចូលទឹកថ្មីចូល) ក្នុងមួយខែម្តង

- ចំណី និងការឱ្យចំណីៈ គាត់ឱ្យចំណី ០២ ដង ក្នុងមួយថ្ងៃដោយប្រើ ចំណីដែលមានគុណភាពខ្ពស់
  - ចំណីសំរេច (ចំណីនាំចូលពីបរទេស)
  - ត្រីនុយ (កូនត្រីល្អិត១)
  - និងចំណីផ្សំដោយប្រើត្រីនុយ លាយជាមួយកន្ទក់
- ចំណីផ្សំគឺត្រូវបានចំអិនហើយប្រើម៉ាស៊ីនកូរ និង កិនទៅជាចំណី គ្រាប់ ឬជារាងទ្រវែងនៅពេលផ្តល់ចំណី។
- ចំនួនដាក់ចិញ្ចឹម គឺប្រមាណ ១០ក្បាល ក្នុងមួយម៉ែត្រការ៉េ
- ការគ្រប់គ្រងស្រះចិញ្ចឹមត្រីៈ តាមដានគុណភាពទឹកស្រះដូចជា ប៉េហាស់ (pH) ពណ៌ទឹក និង ចរិតស៊ីចំណីរបស់ត្រី។

## ករណីទី៤: លោក វេង ឡុង នៅឃុំកំពង់ព្រះ ស្រុកបាធាយ ខេត្តកំពង់ចាម



លោក វេង ឡុង មានស្រះទំហំ ប្រមាណ ២១០០ ម៉ែត្រការ៉េ។ មុនពេលចូលជាមួយគំរោង អេម អេស អេម អ៊ី គាត់អាចប្រមូលផល បានត្រឹមតែ ៣-៤ តោនពីស្រះរបស់ គាត់ មានន័យថាគាត់អាចប្រមូល ផលបានប្រមាណពី ១.៥-២.០ គក្រ ក្នុងមួយម៉ែត្រការ៉េ និងប្រើរយៈ

ពេលប្រមាណ ២ ឆ្នាំ ក្នុងការចិញ្ចឹមត្រី។ បន្ទាប់ពីគាត់អនុវត្តតាមលក្ខណៈបច្ចេកទេស គាត់អាចប្រមូលផលបានប្រមាណ ៨តោន ពីស្រះរបស់គាត់បានន័យថា គាត់អាចបង្កើនទិន្នផលរបស់គាត់ដល់ ៣-៤ គក្រ ក្នុងមួយម៉ែត្រការ៉េ និងប្រើរយៈពេលប្រមាណ ៨ ខែ។ ខាងក្រោមនេះជាបទពិសោធន៍ដែល លោក វ៉េង ឡុង បានអនុវត្តៈ

- ○ រៀបចំស្រះតាមលក្ខណៈបច្ចេកទេសមុនពេលលែងកូនត្រី
- ○ ការប្រើប្រាស់ប្រភពទឹក គាត់ប្រើម៉ាស៊ីនបូមទឹកពីអណ្តូង និងប្រើទឹកភ្លៀង
- ○ ការកែប្រែគុណភាពទឹក គាត់បានផ្លាស់ប្តូរទឹកស្រះ ០១ ដងក្នុងមួយខែ
- ○ ការរៀបចំចំណី និង ការឱ្យចំណី គាត់ឱ្យចំណី ០២ ដងក្នុងមួយថ្ងៃ ដោយប្រើចំណីដែលមាន គុណភាពខ្ពស់។
    - ▪ ត្រីនុយ (កូនត្រីល្អិត១)
    - ▪ ចំណីផ្សំ ត្រីនុយលាយជាមួយកន្ទក់ ចំអិនរួចហើយកូរដោយម៉ាស៊ីនកិនជាគ្រាប់ ឬជារាងទ្រវែងដាក់ឱ្យត្រីស៊ី។
- ○ ចំនួនត្រីដាក់ចិញ្ចឹមៈ ១០ ក្បាល ក្នុងមួយម៉ែត្រការ៉េ
- ○ ការគ្រប់គ្រងស្រះចិញ្ចឹមត្រីៈ តាមដានគុណភាពទឹកស្រះ ដូចជាប៉េហាស់ (pH) ពណ៌ទឹក និងចរិតស៊ីចំណីរបស់ត្រី។

# ឯកសារយោង


○ បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ របស់រដ្ឋបាលជលផល

○ ប្រភេទត្រីទឹកសាបមានតំលៃសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ដោយនាយកដ្ឋានជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ២០០៥

○ ខ្សែវីដេអូស្តីពីការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ផលិតដោយនាយកដ្ឋានជលផលសហការជាមួយ អង្គការ AIT

○ Inland Aquaculture, Handout 2004, Dr. Amararatne Yakupitiyage, Associate Professor, Aquaculture and Aquatic Resources Management, Asian Institute of Technology (AIT)

## ឧបសម្ព័ន្ធ ១ : គំរូកត់ត្រាការវិភាគចំណូល ចំណាយ សម្រាប់មុខរបរចិញ្ចឹមត្រី

ចំណាយប្រចាំខែ និង ចំណាយប្រចាំឆ្នាំសម្រាប់ ____________ ចាប់ពី .................. ដល់ ..................

| **ប្រភេទចំណាយ** | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ការរៀបចំស្រះ** | | | | | | | | | | | | | |
| កំលាំងពលកម្ម | | | | | | | | | | | | | |
| ម៉ាស៊ីនបូមទឹក | | | | | | | | | | | | | |
| ប្រេងឥន្ធនៈសម្រាប់ម៉ាស៊ីនបូមទឹក | | | | | | | | | | | | | |
| កំបោរ | | | | | | | | | | | | | |
| ជីលាមកសត្វ និង ជីគីមី | | | | | | | | | | | | | |
| **តំលៃកូនត្រីពូជ** | | | | | | | | | | | | | |
| កូនត្រីពូជ | | | | | | | | | | | | | |
| ថ្លៃដឹកជញ្ជូន | | | | | | | | | | | | | |
| កំលាំងពលកម្ម | | | | | | | | | | | | | |
| **ចំណាយលើចំណី** | | | | | | | | | | | | | |
| សារធាតុផ្សំនៃចំណី | | | | | | | | | | | | | |
| ចង្ក្រាន និង ខ្ទះចំអិនចំណី | | | | | | | | | | | | | |
| ប្រេងឥន្ធនៈ | | | | | | | | | | | | | |
| ម៉ាស៊ីនកិនចំណី | | | | | | | | | | | | | |
| **ការគ្រប់គ្រងគុណភាពទឹកស្រះ** | | | | | | | | | | | | | |
| ជីលាមកសត្វ ឬជីគីមី | | | | | | | | | | | | | |
| ម៉ាស៊ីនបូមទឹក | | | | | | | | | | | | | |
| ថ្នាំការពារ និង ព្យាបាលជម្ងឺត្រី | | | | | | | | | | | | | |
| កំលាំងពលកម្ម | | | | | | | | | | | | | |
| ថ្លៃប្រមូលផល | | | | | | | | | | | | | |
| ចំណាយផ្សេងៗ | | | | | | | | | | | | | |
| **សរុប** | | | | | | | | | | | | | |